# លទ្ធផលនៃការសង្កេតដោយសង្ខេប

បន្ទាប់ពីជាប់គាំង និងខ្វះនីត្យានុកូលភាពនៃការបង្កើតរដ្ឋសភារយៈពេលពីក្រោយការបោះឆ្នោត ខែកក្កដា ឆ្នាំ២០១៣ ដល់ខែកក្កដា ឆ្នាំ២០១៤ នៅក្នុងឆ្នាំទី១នៃនីតិកាលទី៥ រចនាសម្ព័ន្ធដឹកនាំនៃរដ្ឋសភា ប្រធាន អនុប្រធានទាំង២នៃរដ្ឋសភា រួមទាំងគណៈកម្មការអចិន្ត្រៃយ៍ ប្រធាន និងអនុប្រធានទាំង១០ នៃគណៈកម្មការជំនាញនានារបស់រដ្ឋសភាគឺត្រូវបានបង្កើត និងបែងចែកអំណាចក្នុងចំណោមគណបក្សទាំងពីរដែលមានអាសនៈក្នុងរដ្ឋសភា នៅខែសីហា ឆ្នាំ២០១៤ ជាពិសេសប្រធាន និងអនុប្រធានទី២រដ្ឋសភា ត្រូវបានដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ចំណែកឯអនុប្រធានទី១នៃរដ្ឋសភា ដឹកនាំដោយគណបក្សសង្គ្រោះជាតិ។

ការផ្លាស់ប្តូរតំណាងរាស្ត្រនៅក្នុងបញ្ជីរបស់គណបក្សនយោបាយ និងថ្នាក់ដឹកនាំរដ្ឋសភា (អនុប្រធានរដ្ឋសភា) ធ្វើឡើងដោយមិនមានតម្លាភាព និងមិនមាននីតិវិធីច្បាស់លាស់ នៅខណៈដែលអ្នកតំណាងរាស្ត្រមិនមានអំណាច ប៉ុន្តែបានផ្តល់អំណាចយ៉ាងធំធេងដល់ប្រធានគណបក្សនយោបាយ។

នៅក្នុងអំឡុងខែកក្កដា ឆ្នាំ២០១៤ បេក្ខជនជាប់ឆ្នោតប្រាំពីរ (៧)រូប នៃគណបក្សសង្គ្រោះជាតិរួមមាន លោកស្រី មូរ សុខហួរ លោក ម៉ែន សុថាវរិន្ទ្រ លោក ហូរ វ៉ាន់ លោក រៀល ខេមរិន្ទ្រ លោក កែវ ភីរម្យ លោក ឡុង រី និង លោក នុត រំដួល ត្រូវបានសាលាដំបូងរាជធានីភ្នំពេញចាប់ឃុំខ្លួន និងធ្វើការចោទប្រកាន់។ ការចាប់ខ្លួននោះមានការចោទប្រកាន់រាជរដ្ឋាភិបាលថា ជាចេតនាដើម្បីចាប់បង្ខំឲ្យចូលតុចរចា បន្ទាប់ពីបានជាប់គាំងនយោបាយជាច្រើនខែនៅក្រោយការបោះឆ្នោត ហើយករណីនេះត្រូវទទួលការរិះគន់ជាខ្លាំង និងត្រូវបានមើលឃើញថា ជារឿងនយោបាយ។ ទោះជាយ៉ាងណា អ្នកទាំងនោះត្រូវបានដោះលែងវិញភ្លាមៗនៅបន្ទាប់ពីកិច្ចចរចាថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ប៉ុន្តែតុលាការនៅបន្តនីតិវិធីរបស់ខ្លួន ដោយបានកោះហៅអ្នកទាំងនោះទៅបំភ្លឺនៅតុលាការនៅក្រោយការដោះលែង និងព្រមទាំងមានការចាប់ខ្លួនមន្ត្រី និងសកម្មជនគណបក្សសង្គ្រោះជាតិជាបន្តបន្ទាប់ទាក់ទងករណីដូចគ្នានេះ។

ក្នុងដំណើរការរដ្ឋសភាក្នុងឆ្នាំទីមួយនៅ បន្ទាប់ពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៥ ស្ថាប័នមួយនេះ ត្រូវបានអ្នកវិភាគឯករាជ្យ និងអ្នកឃ្លាំមើលដំណើរការរបស់រដ្ឋសភាបានមើលឃើញថា មិនបានដោះស្រាយបញ្ហាប្រឈមនានារបស់ប្រជាពលរដ្ឋ ដូចជាបញ្ហាដីធ្លី ការបាញ់សម្លាប់ប្រជាពលរដ្ឋនៅផ្លូវវេងស្រេង និងការរំលោភសិទ្ធិមនុស្សជាដើម។ តំណាងរាស្ត្រមួយចំនួន មិនបានអនុវត្តតាមតួនាទីរបស់ខ្លួនទេ នៅពេលដែលពលរដ្ឋរងទុក្ខ ហើយរត់ទៅពឹងពាក់តំណាងរាស្ត្ររបស់ខ្លួនឲ្យជួយ។

បន្ទាប់ពីក្រុមតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិសម្រេចចិត្តចូលរដ្ឋសភានៅខែសីហា ឆ្នាំ២០១៤ ក្បាលម៉ាស៊ីននាំដឹកនាំអង្គនីតិបញ្ញត្តិមួយនេះ ត្រូវបានរៀបចំឡើងវិញ ដោយមានការបែងចែកតួនាទីនៅក្នុងគណៈកម្មា

ធិការអចិន្ត្រៃនៃរដ្ឋសភា តាមរូបមន្ត៧ទល់៦។ គណៈកម្មការជំនាញថ្មីមួយទៀត ត្រូវបានបង្កើតក្រោមការដឹកនាំដោយសមាជិករដ្ឋសភាពីគណបក្សសង្គ្រោះជាតិ។

គណៈកម្មការជំនាញថ្មីនោះ គឺគណៈកម្មការទី១០ មានឈ្មោះថា គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយដែលបានបំបែកចេញពីគណៈកម្មការជំនាញទី៤។ ទន្ទឹមនឹងនេះ គណៈកម្មការជំនាញទី៤ ត្រូវបានប្ដូរឈ្មោះជាគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ ដោយតួនាទីមួយផ្នែក ត្រូវបានកាត់បញ្ចូលទៅគណៈកម្មការដែលទើបបង្កើតថ្មី។ គណៈកម្មការជំនាញដែលគណបក្សប្រជាជនកម្ពុជាធ្វើជាប្រធាន និងជាលេខាធិការនោះ រួមមាន គណៈកម្មការទី២ គណៈកម្មការទី៤ គណៈកម្មការទី ៥ គណៈកម្មការទី៦ និងគណៈកម្មការទី៩។ ចំណែកឯគណៈកម្មការជំនាញដែលដឹកនាំដោយគណបក្សសង្គ្រោះជាតិធ្វើជាប្រធាន និងជាលេខាធិការរួមមានដូចជា គណៈកម្មការទី១ គណៈកម្មការទី៣ គណៈកម្មការទី៧ គណៈកម្មការទី៨ និងគណៈកម្មការទី១០។

បន្ទាប់ពីគណៈកម្មការជំនាញមួយចំនួននៃរដ្ឋសភាត្រូវបានដឹកនាំដោយគណបក្សសង្គ្រោះជាតិ គណៈកម្មការទាំងនោះបានធ្វើសកម្មភាពយ៉ាងសកម្មក្នុងការកោះហៅរដ្ឋមន្ត្រី ឬតំណាងរាជរដ្ឋាភិបាលមកបំភ្លឺនៅក្នុងគណៈកម្មការ ដើម្បីធ្វើការសាកសួរ និងពិភាក្សារកដំណោះចំពោះបញ្ហាសង្គមមួយចំនួន ជាពិសេសបញ្ហាទំនាស់ដីធ្លី។

ប្រហាក់ប្រហែលនីតិកាលទី៤ នៃរដ្ឋសភា ការលំបាកក្នុងការទំនាក់ទំនងសាកសួរ និងទទួលព័ត៌មានផ្លូវការពីអគ្គលេខាធិការដ្ឋានរបស់រដ្ឋសភា ជាមួយតំណាងរាស្ត្រ ពិសេសតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា។ ខុទ្ទកាល័យ និងអគ្គលេខាធិការដ្ឋាន ដែលគ្រប់គ្រងដោយគណបក្សសង្គ្រោះជាតិ គឺមានការងាយស្រួលក្នុងការទំនាក់ទំនងជាមួយតំណាងរាស្ត្ររបស់ខ្លួន។

**ការប្រជុំពេញអង្គរដ្ឋសភាឯកបក្ស និងខ្វះនិត្យានុកូលភាព៖** រដ្ឋសភានីតិកាលទី៥ ក្នុងឆ្នាំទី១នេះ (ពីខែកញ្ញា ឆ្នាំ២០១៣ ខែកក្កដា ឆ្នាំ២០១៤) បានបើកសម័យប្រជុំពេញអង្គសាមញ្ញរបស់ខ្លួនចំនួន២លើក និងប្រជុំពេញអង្គវិសាមញ្ញចំនួន ១លើក។ សម័យប្រជុំពេញអង្គលើកទី១ចន្លោះពេលពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០១៣ និងលើកទី២ ចន្លោះខែមេសា ដល់ខែមិថុនា ឆ្នាំ២០១៤។ រដ្ឋសភាឯកបក្សដែលមានតែគណបក្សប្រជាជនកម្ពុជាបានអនុម័តច្បាប់ដ៏ចម្រូងចម្រាសចំនួនបីទាក់ទងវិស័យតុលាការ និងច្បាប់ថវិកាជាតិគ្រប់គ្រងឆ្នាំ២០១៤។

ការប្រជុំពេញអង្គរដ្ឋសភាដែលមានទម្រង់ពេញលេញ គឺនៅពេលដែលគណបក្សទទួលអាសនៈក្នុងរដ្ឋសភាទាំងពីរបានចូលរួមក្នុងដំណើរការរបស់រដ្ឋសភាពីខែសីហា ដល់ខែតុលា ឆ្នាំ២០១៤។ ការសង្កេតឃើញថា មានកិច្ចប្រជុំពេញអង្គចំនួន៣លើក ដែលក្នុងនោះប្រជុំវិសាមញ្ញចំនួន២លើក (ទី១.ពិភាក្សា និងអនុម័តវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងទី២.ការបោះឆ្នោតជ្រើសតាំងអនុប្រធានទី១ និងទី២នៃរដ្ឋសភា និងការបោះឆ្នោតជ្រើសតាំងជំនួស និងបំពេញបន្ថែមសមាជិកគណៈកម្មការនានានៃរដ្ឋសភា) និងប្រជុំសាមញ្ញចំនួន១លើក ដោយ

បានពិភាក្សា និងអនុម័តរបៀបវារៈចំនួន៤ ដែលក្នុងនោះ វិសោធនកម្មច្បាប់ចំនួនពីរ និងផ្ដល់សច្ចាប័នលើកិច្ចព្រមព្រៀងចំនួនពីរ។

រដ្ឋសភាមានរបៀបវារៈចំនួន៣៦របៀបវារៈ ដែលតម្រូវយកមកពិភាក្សា និងអនុម័ត និងរួមទាំងការបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្ត។ ក្នុងរបៀបវារៈទាំង៣៦ រដ្ឋសភាយកមកពិភាក្សា និងអនុម័តនោះរួមមាន សេចក្ដីព្រាងច្បាប់ចំនួន១៤ ការផ្ដល់សច្ចាប័នលើកិច្ចព្រមព្រៀងចំនួន១៤ច្បាប់ ការបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តចំនួន៤លើក វិសោធនកម្មច្បាប់ចំនួន៣ច្បាប់ និងការឆ្លើយបំភ្លឺផ្ទាល់មាត់នៅក្នុងសភាចំនួន១លើក។ ក្នុងឆ្នាំទី១នីតិកាលទី៥នេះ រដ្ឋសភាជាតិមិនសូវមមាញឹកក្នុងការប្រជុំពិភាក្សា និងអនុម័តច្បាប់នោះទេ ក្នុងអំឡុងរយៈពេលរបាយការណ៍ខុមហ្វ្រែល រដ្ឋសភាបានដំណើរការកោះអញ្ជើញតំណាងរាស្ត្រចូលរួមកិច្ចប្រជុំបានចំនួន១១លើកដំណើរការកិច្ចប្រជុំ២០កិច្ចប្រជុំ។ តែបើគិតជាមធ្យមក្នុង១កិច្ចប្រជុំ ចំណាយពេលវេលាត្រឹមតែ១ព្រឹកប៉ុណ្ណោះក្នុងការពិភាក្សា និងអនុម័តលើសេចក្ដីព្រាងច្បាប់/ស្នើច្បាប់នានាដែលចូលរដ្ឋសភា។

មួយឆ្នាំនេះ កិច្ចប្រជុំរដ្ឋសភា មានតំណាងរាស្ត្រចំនួន២៣រូប (ស្មើនឹង១៩%) នៃចំនួនអ្នកតំណាងរាស្ត្រសរុបនៅក្នុងរដ្ឋសភា បានចំណាយពេលឡើងបញ្ចេញមតិចំនួន៨៨ដង ប្រើប្រាស់ពេលវេលាអស់៦៩៣នាទី(ស្មើនឹង១១ម៉ោង៣៣នាទី)។ ក្នុងនោះមានតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាចំនួន១៩រូប បានឡើងបញ្ចេញមតិសរុបចំនួន៦៣២នាទី(ស្មើនឹង១០ម៉ោង៣២នាទី) និងតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ចំនួន៤រូប បានឡើងបញ្ចេញមតិចំនួន៦១នាទី(ស្មើនឹង១ម៉ោង១នាទី)។ សូមបញ្ជាក់ថា ក្នុងកិច្ចប្រជុំរបស់រដ្ឋសភាទាំង២០កិច្ចប្រជុំនោះ តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិបានចូលរួមប្រជុំចំនួន០៥កិច្ចប្រជុំចាប់ពីតំណាងរាស្ត្រគណបក្សនេះចូលសភា និងបានចូលរួមពិភាក្សា និងអនុម័តច្បាប់ចំនួន០៥ច្បាប់ និងបោះឆ្នោតចំនួន០២លើក (បោះឆ្នោតជូនលោក ងួន ញ៉ិល ជាអនុប្រធានទី២ និងលោក កឹម សុខា ជាអនុប្រធានទី១នៃរដ្ឋសភា និងបោះឆ្នោតបំពេញបន្ថែមសមាជិកគណៈកម្មការជំនាញនៃរដ្ឋសភា។

**ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ:** តាមរយៈការប្រមូលព័ត៌មានរបស់ខុមហ្វ្រែលទទួលបាន មានអ្នកតំណាងរាស្ត្រចុះមូលដ្ឋានចំនួន១២៧៤លើក ដែលក្នុងនោះ សកម្មភាពរបស់អ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិចំនួន ៦៦៤លើក គណបក្សប្រជាជនកម្ពុជាចំនួន៦១០លើក។

ព័ត៌មានអំពីការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ អ្នកសង្កេតការណ៍ខុមហ្វ្រែលបានប្រមូលពីការិយាល័យតំណាងរាស្ត្រតាមបណ្ដារាជធានី ខេត្ត ពីស្នាក់ការគណបក្សនយោបាយប្រចាំរាជធានី ខេត្ត ពីប្រព័ន្ធផ្សព្វផ្សាយនានា និងពីជំនួយការអ្នកតំណាងរាស្ត្រផ្ទាល់ ទៅតាមលទ្ធភាព និងមធ្យោបាយដែលអ្នកសង្កេតការណ៍អាចធ្វើបាន។ ដូច្នេះព័ត៌មានដែលយើងខ្ញុំទទួលបានពីការចុះមូលដ្ឋានរបស់តំណាងរាស្ត្រទាំងពីរគណបក្សនេះ អាចតិចជាងចំនួនចុះជាក់ស្ដែង ដោយហេតុថា ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រភាគច្រើន គឺមិនបានផ្ដល់សកម្មភាពព័ត៌មានជាក់លាក់ទៅឱ្យមន្ត្រីការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលនោះឡើយ

ហើយអ្នកសង្កេតការណ៍ខុមហ្វ្រែលក៏ជួបការលំបាកក្នុងការប្រមូលព័ត៌មានពីអ្នកតំណាងរាស្ត្រមួយចំនួន ជាពិសេសរបាយការណ៍សកម្មភាពរបស់អ្នកតំណាងរាស្ត្រនៃគណបក្សប្រជាជនកម្ពុជា។

ក្នុងចំណោមសកម្មភាពចុះមូលដ្ឋានទាំង១២៧៤លើក គឺមានតំណាងរាស្ត្រចំនួន៩៦រូប ក្នុងចំណោមតំណាងរាស្ត្រសរុប១២៣រូប បានធ្វើសកម្មភាពទៅលើគោលបំណងចំនួន៥ រួមមាន ១.ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយប្រជាពលរដ្ឋ និងការសម្ពោធសមិទ្ធផលនានា ២.ការចុះពង្រឹងបណ្តាញផ្ទៃក្នុងបក្ស ៣.ការចូលរួមវេទិកាសាធារណៈ ៤.ការអមដំណើរថ្នាក់ដឹកនាំ និង៥.ការចុះជួយអន្តរាគមន៍ដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

ដើមនីតិកាលទី៥នេះ គណបក្សប្រជាជនកម្ពុជាទទួលបានអាសនៈក្នុងរដ្ឋសភាចំនួន៦៨រូប ខុមហ្វ្រែលទទួលព័ត៌មាន មានតំណាងរាស្ត្រចំនួន៥០រូប ចុះធ្វើសកម្មភាពក្នុងមូលដ្ឋានបានចំនួន៦១០លើក។ បើគិតជាមធ្យមក្នុង១រូប តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាចុះបាន១២លើក។ គណបក្សសង្គ្រោះជាតិដែលមានអាសនៈក្នុងរដ្ឋសភាចំនួន៥៥រូប មានតំណាងរាស្ត្រចំនួន៤៦រូប បានចុះធ្វើសកម្មភាពក្នុងមូលដ្ឋានរបស់ខ្លួនចំនួន៦៦៤លើក។ បើគិតជាមធ្យមតំណាងរាស្ត្រ១រូប ចុះធ្វើសកម្មភាពការងារក្នុងមូលដ្ឋានបានចំនួន១៤លើក។

ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា គឺបានផ្តោតទៅលើការចុះសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋ រួមទាំងសម្ពោធសមិទ្ធផលនានាដោយចុះបាន៣៥៩លើក។ ចំណែកគោលបំណងទី២ផ្តោតទៅលើការចុះអមដំណើរថ្នាក់ដឹកនាំបានចំនួន១៦៨លើក។ គោលបំណងចុះពង្រឹងបណ្តាញផ្ទៃក្នុងបក្សបានចំនួន៥៧លើក ចូលរួមវេទិកាសាធារណៈចំនួន៥លើក និងជួយអន្តរាគមន៍ដោះស្រាយបញ្ហានានាបានចំនួន២១លើក។ រីឯតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិចុះមូលដ្ឋាន ក្នុងគោលបំណងផ្តោតទៅលើការចុះសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋ និងចែកអំណោយដល់ប្រជាពលរដ្ឋម្ចាស់ឆ្នោតចំនួន៣៤៨លើក និងគោលបំណងទី២តំណាងរាស្ត្រគណបក្សនេះ បានផ្តោតទៅលើការចុះពង្រឹងបណ្តាញផ្ទៃក្នុងបក្សបានចំនួន២០៩លើក។ ចំណែកក្នុងគោលបំណង៣ទៀត គឺគោលបំណងអមដំណើរថ្នាក់ដឹកនាំតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិចុះបានចំនួន៧៧លើក គោលបំណងជួយដោះស្រាយបញ្ហានានាបានចំនួន២៧លើក និងក្នុងគោលបំណងចូលរួមវេទិកាបានចំនួន៣លើក។

**ការចេញលិខិតអន្តរាគមន៍របស់តំណាងរាស្ត្រ:** ខុមហ្វ្រែលបានទទួលព័ត៌មានពីការចេញលិខិតរបស់តំណាងរាស្ត្រ បានបង្ហាញឱ្យឃើញថា មានតែតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិប៉ុណ្ណោះ ដែលបានចេញលិខិតទៅក្រសួង ស្ថាប័ននីតិប្រតិបត្តិ អំពាវនាវឱ្យមានអន្តរាគមន៍ទៅលើបញ្ហានានារបស់ប្រជាពលរដ្ឋ។

មានតំណាងរាស្ត្រចំនួន១១រូប មកពីគណបក្សសង្គ្រោះជាតិបានចេញលិខិតចំនួន១៨ច្បាប់ ដែលក្នុងនោះមានលិខិតគោលបំណងអំពាវនាវចំនួន១៣ច្បាប់ លិខិតបញ្ចេញមតិចំនួន១ច្បាប់ និងលិខិតគោលបំណងហៅ

រដ្ឋមន្រ្តីមកឆ្លើយបំភ្លឺចំនួន៤ច្បាប់។ ក្នុងចំណោមលិខិតទាំងនោះ ការសង្កេតឃើញថា មានតែលិខិតចំនួន៥ច្បាប់ប៉ុណ្ណោះ មានការឆ្លើយតបពីរាជរដ្ឋាភិបាល។

**ព័ត៌មានអំពីស្ថានភាពអ្នកតំណាងរាស្ត្រ:** សម្រាប់រដ្ឋសភានីតិកាលទី៥នេះ ខុមហ្វ្រែលបានបន្តចងក្រងជាសៀវភៅប្រវត្តិរូបសង្ខេបរបស់តំណាងរាស្ត្រ ដើម្បីផ្តល់ឱ្យសហគមន៍ អង្គការ ស្ថាប័ន ជាពិសេសប្រជាពលរដ្ឋនូវឧបករណ៍ និងព័ត៌មានចាំបាច់នានា ក្នុងការធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងអំពីដំណើរការ រចនាសម្ព័ន្ធ តួនាទី សិទ្ធិ និងអំណាចរបស់រដ្ឋសភា និងតំណាងរាស្ត្រ។ ព័ត៌មានចាំបាច់មួយចំនួនរបស់អ្នកតំណាងរាស្ត្រ ដូចជាប្រវត្តិសង្ខេប អាសយដ្ឋាន លេខទូរស័ព្ទ កម្រិតវប្បធម៌ ជំនាញឯកទេស វិស័យដែលអ្នកតំណាងរាស្ត្រមានចំណាប់អារម្មណ៍ និងបទពិសោធន៍ការងារជាងដើម ត្រូវរៀបរាប់ក្នុងសៀវភៅនេះ ដើម្បីជួយបង្កើននូវការយល់ដឹងកាន់តែធំធេងឡើងសម្រាប់ម្ចាស់ឆ្នោត និងជាស្ពានទំនាក់ទំនងរវាងអ្នកតំណាងរាស្ត្រជាមួយប្រជាពលរដ្ឋ សហគមន៍ ស្ថាប័ន និងអង្គការនានា។

## អនុសាសន៍

ដើម្បីអនុវត្តកំណែទម្រង់រដ្ឋសភា ដែលព្រមព្រៀងដោយគណបក្សទាំងពីរថា នាំឲ្យដំណើររដ្ឋសភាមានប្រសិទ្ធភាព និងតម្លាភាព ស្របតាមគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស និងរបបសភានិយមនៅកម្ពុជា អនុសាសន៍សំខាន់ៗចូលរួមលើការធ្វើវិសោធនកម្មកែប្រែ ឬការបន្ថែមខ្លឹមសារមាត្រាច្បាប់រដ្ឋធម្មនុញ្ញ និងប្រការបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងមាត្រា១២០ថ្មីនៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដូចខាងក្រោម៖

- សមាជិករដ្ឋសភា ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ដោយសារសាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិករដ្ឋសភា ហើយបញ្ជាក់ពីមូលហេតុ និងផ្សព្វផ្សាយជាសាធារណៈ។ សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ដែលមានការសម្រេចជាលាយលក្ខណ៍អក្សរ តែមិនមែនមូលហេតុដោយសារការបញ្ចេញមតិខុសឆ្គង។ (មាត្រា ១២០ថ្មី នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ)
- យ៉ាងយូរបី(០៣)ថ្ងៃ ក្រោយពេលការប្រកាសលទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាស្ថាពរ គណៈកម្មាធិការជាតិសម្រាប់ការបោះឆ្នោត ត្រូវរៀបចំបញ្ជីសមាជិកតំណាងរាស្ត្រដែលមានយ៉ាងតិច១២០រូបថ្វាយព្រះមហាក្សត្រ។ (វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ)
- ការអនុម័តបទបញ្ជាផ្ទៃក្នុង«ថ្មី» ត្រូវការមតិពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ក្នុងករណីមិនមានបទបញ្ជាផ្ទៃក្នុងថ្មី បទបញ្ជាផ្ទៃក្នុងនៃអាណត្តិចុងក្រោយត្រូវចូលជាធរមាន។ (មាត្រា៨២ថ្មី នៃរដ្ឋធម្មនុញ្ញ និងប្រការ ៨២ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)។
- បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ត្រូវចែងអំពីការបែងចែកអំណាចដឹកនាំរដ្ឋសភាសមាមាត្រ ក្នុងចំណោមគណបក្សមានអាសនៈក្នុងរដ្ឋសភារវាងគណបក្សប្រឆាំង និងគណបក្សកាន់អំណាច ខណៈដែលបញ្ចូលសមាស

ភាពបុរស និងស្ត្រី ដូចរូបមន្តកិច្ចព្រមព្រៀងដំណោះស្រាយនយោបាយថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤។ (ប្រការ ០២ថ្មី (ពីរ) និង ១០ថ្មី(ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)។

- គណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មការជំនាញនីមួយៗ នៃរដ្ឋសភាត្រូវកំណត់ពេល ០១ (មួយ) ថ្ងៃ ក្នុង ០១ (មួយ) សប្តាហ៍ ដើម្បីធ្វើសវនាការសាធារណៈ ជជែកដេញដោល ដោយកោះហៅជនពាក់ព័ន្ធមកបំភ្លឺលើសេចក្តីព្រាង និងសេចក្តីស្នើច្បាប់ និងការអនុវត្តច្បាប់ជាធរមាន។ គណៈកម្មាធិការអចិន្ត្រៃយ៍មានអំណាចទទួលពិនិត្យបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា។ (ប្រការថ្មីបមន្ថែមក្នុងជំពូក៣ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)
- កំណត់ហេតុទាំងអស់ និងឯកសារដទៃទៀតរបស់រដ្ឋសភា ត្រូវរក្សាទុកនៅក្នុងអគ្គលេខាធិការដ្ឋាន និងជាសាធារណៈ លើកលែងតែជាកំណត់ហេតុ និងឯកសារទាំងឡាយណាដែលសំរេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍ថា អាចប៉ះពាល់ដល់សន្តិសុខជាតិ។ (ប្រការ១៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)។ អគ្គលេខាធិការដ្ឋានត្រូវរៀបចំឲ្យមានបទបញ្ជារដ្ឋបាល ដើម្បីធានាសិទ្ធិប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាន និងចូលរួមក្នុងព្រឹត្តិការណ៍សាធារណៈរបស់រដ្ឋសភា។(ប្រការថ្មី បញ្ចូលទៅក្នុងជំពូកទី ៤)។
- គណៈកម្មការជំនាញនៃរដ្ឋសភា ត្រូវកោះហៅអ្នកព្រាងច្បាប់ និងអ្នកស្នើច្បាប់មកសាកសួរអំពីសេចក្តីព្រាង និងសេចក្តីស្នើច្បាប់ក្នុង«សវនាការសាធារណៈ» ដោយមានការចូលរួមពីអ្នកសង្កេតការណ៍ និងតំណាងប្រជាពលរដ្ឋ។ អ្នកតែងសេចក្តីព្រាងច្បាប់ ឬអ្នកតែងសេចក្តីស្នើច្បាប់ មានសិទ្ធិចូលរាយការណ៍ជម្រាបគណៈកម្មការដែលពិនិត្យសេចក្តីស្នើច្បាប់នោះ។ (ប្រការ២៣ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)
- ចម្លើយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រី ត្រូវធ្វើឡើងក្នុងរយៈពេល(១៥)ដប់ប្រាំថ្ងៃបន្ទាប់ពីទទួលបានសំណួរ។ ចំពោះចម្លើយផ្ទាល់មាត់តំណាងរាស្ត្រដាក់សំណួរ និងរាជរដ្ឋាភិបាលមានសិទ្ធិទទួលបានពេលវេលាស្មើគ្នាក្នុងការជជែកដេញដោល។ ចំពោះចម្លើយជាលាយលក្ខណ៍អក្សរតំណាងរាស្ត្រដាក់សំណួរមានសិទ្ធិឆ្លើយតបក្នុងរដ្ឋសភា ក្នុងរយៈពេលស្មើគ្នានឹងការអានចម្លើយជាលាយលក្ខណ៍អក្សររបស់រាជរដ្ឋាភិបាល។ ប្រធានក្រុមភាគតិចនៅរដ្ឋសភា ពិភាក្សា និងដេញដោលជាមួយនាយករដ្ឋមន្ត្រីតទល់មុខគ្នា។
- ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួន(៣០)សាមសិបយ៉ាងតិច ទើបរដ្ឋសភាលើកយកមកពិភាក្សាបាន។ ប្រសិនបើមានញត្តិបន្ទោសសមាជិកគណៈរដ្ឋមន្ត្រី ឬរាជរដ្ឋាភិបាលពីរដង រដ្ឋសភាត្រូវបើកប្រជុំពេញអង្គពិភាក្សា និងអនុម័តជាសាធារណៈក្នុងការទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬរាជរដ្ឋាភិបាល។ (ប្រការ៣៥ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)
- គណៈបក្សនយោបាយមានអាសនៈក្នុងរដ្ឋសភាតិចជាងដប់ មានសិទ្ធិបង្កើតក្រុមរបស់ខ្លួនចំនួនមួយ(០១)ក្រុម ដើម្បីអាចចូលរួមពិភាក្សាច្បាប់ក្នុងការប្រជុំពេញអង្គ។ (ប្រការ៤៨ថ្មី (ពីរ) បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)

- លុបចោលសារាចរណែនាំ ស្ដីពីបែបបទការងារស្ដីពីគណៈកម្មការនានានៃរដ្ឋសភា ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ ចេញដោយប្រធានរដ្ឋសភា។

**មាតិកាសំខាន់ៗ**


I. ដំណើរការប្រជុំរបស់រដ្ឋសភា ទំព័រទី ៧
II. ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ទំព័រទី ១៧
III. ការទំនាក់ទំនង និងអន្តរាគមន៍របស់អ្នកតំណាងរាស្ត្រ និងរដ្ឋសភា ទំព័រទី ២២
IV. អំពីអ្នកតំណាងរាស្ត្រ ទំព័រទី ២៧
V. ការផ្លាស់ប្ដូរថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពតំណាងរាស្ត្រ ទំព័រទី ២៨
VI. សង្ខេបព្រឹត្តិការណ៍សំខាន់ៗទាក់ទងសភា និងតំណាងរាស្ត្រ ទំព័រទី ៣២


**រូបសញ្ញាគណបក្សប្រើក្នុងរបាយការណ៍នេះ**

គណបក្ស ប្រជាជនកម្ពុជា

គណបក្ស សង្គ្រោះជាតិ

# រដ្ឋសភា និងតំណាងរាស្ត្រ

## I.ដំណើរការប្រជុំរបស់រដ្ឋសភា

រដ្ឋសភានីតិកាលទី៥ ក្នុងដើមឆ្នាំទី១នេះ ក្នុងចន្លោះពេលពីខែតុលា ២០១៣ ដល់ខែកញ្ញា ២០១៤ រដ្ឋសភាបានបើកសម័យប្រជុំពេញអង្គសាមញ្ញរបស់ខ្លួនចំនួន២លើក (លើកទី១ ក្នុងចន្លោះពេលពីខែតុលា ដល់ខែធ្នូឆ្នាំ ២០១៣ និងលើកទី២ចាប់ពីចន្លោះខែមេសា ដល់ខែមិថុនា ឆ្នាំ២០១៤) និងបានបើកកិច្ចប្រជុំជាវិសាមញ្ញចំនួន៣លើក ដែលលើកទី១នៅថ្ងៃទី២៨ កក្កដា ២០១៣ លើកទី២នៅថ្ងៃទី៨ សីហា ២០១៤ និងលើកទី៣ចាប់ពីថ្ងៃទី២៦ ដល់២៧ សីហា ២០១៤ ក្នុងចន្លោះសម័យប្រជុំពេញអង្គលើកទី២និងលើកទី៣នៃនីតិកាលទី៥រដ្ឋសភាជាតិ។

រដ្ឋសភាមានរបៀបវារៈចំនួន៣៦របៀបវារៈ ដែលតម្រូវយកមកពិភាក្សា និងអនុម័ត និងរួមទាំងបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្ត។ ក្នុងរបៀបវារៈទាំង៣៦ រដ្ឋសភាយកមកពិភាក្សា និងអនុម័តនោះរួមមានសេចក្ដីព្រាងច្បាប់ចំនួន១៤ច្បាប់ ការផ្ដល់សច្ចាប័នលើកិច្ចព្រមព្រៀងចំនួន១៤ច្បាប់ ការបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តចំនួន៤លើក វិសោធនកម្មច្បាប់ចំនួន៣ច្បាប់ និងការឆ្លើយបំភ្លឺផ្ទាល់មាត់នៅក្នុងសភាចំនួន១លើក។

រាល់កិច្ចប្រជុំពេញអង្គរដ្ឋសភាក្នុងឆ្នាំទី១ដើមនីតិកាលទី៥នេះ រដ្ឋសភាមិនមានការជួបវិបត្តិក្នុងការខ្វះកូរ៉ុមសម្រាប់កិច្ចប្រជុំរបស់ខ្លួននោះទេ ទោះបីតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិនៅមិនចូលរដ្ឋសភាក៏ដោយ រដ្ឋសភានៅតែអាចបន្តកិច្ចប្រជុំនិងអនុមត័ច្បាប់ដដែរ រដ្ឋសភាដំណើរការទៅមុខតែឯកបក្ស ពោលគឺមានតែតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាតែមួយប៉ុណ្ណោះ ដែលជាគណបក្សដឹកនាំស្ថាប័ននីតិប្រតិបត្តិ។

### ១.១ ការប្រជុំពេញអង្គ/ ការប្រជុំដេញដោល ឬការឆ្លើយបំភ្លឺ

ក្នុងរយៈពេលនេះ រដ្ឋសភាបានហៅរដ្ឋមន្ត្រីមកបំភ្លឺដោយផ្ទាល់មាត់នៅក្នុងរដ្ឋសភាពាក់ព័ន្ធនឹងការអភិវឌ្ឍន៍គម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២។ ការកោះហៅនេះ គឺធ្វើឡើងយដោយក្រុមអ្នកតំណាងរាស្ត្រចំនួន៤៧រូបរបស់គណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សដឹកនាំរាជរដ្ឋាភិបាល។ គួរកត់សម្គាល់ថា នេះជាលើកដំបូងហើយដែលក្រុមតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានកោះហៅតំណាងរាជរដ្ឋាភិបាលមកឆ្លើយបំភ្លឺនៅរដ្ឋសភា។

ការឆ្លើយបំភ្លឺដោយផ្ទាល់មាត់នេះ មានសំណួរចំនួន៥ ត្រូវបានប្រធានរដ្ឋសភាអនុញ្ញាតឱ្យក្រុមតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាសាកសួរទៅរដ្ឋមន្ត្រី។ ជាមួយគ្នានេះ ប្រធានរដ្ឋសភាក៏តម្រូវឱ្យតំណាងរាជរដ្ឋាភិបាលធ្វើការឆ្លើយបំភ្លឺម្តងមួយសំណួរៗ ដោយប្រើប្រាស់ពេលវេលា ៣០នាទី។

តាមប្រការ ៣២ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាបានចែងថា« អ្នកតំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល។ សំណួរនេះត្រូវសរសេរជាលាយលក្ខណ៍អក្សរប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា។ ចម្លើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូប ឬច្រើនរូបអាស្រ័យដោយបញ្ហាដែលបានចោទឡើង ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូប ឬច្រើនរូប។ ចំពោះចម្លើយផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសម្រេចបើកឲ្យមាន ឬមិនឲ្យមានការជជែកដេញដោល។ បើគ្មានការបើកឲ្យជជែកដេញដោលទេ នោះចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រីនឹងបញ្ចប់សំណួរតែម្តង។»

ការកោះហៅរាជរដ្ឋាភិបាលមកបំភ្លឺផ្ទាល់មាត់នៅរដ្ឋសភា ដែលធ្វើឡើងដោយតំណាងរាស្ត្រគណបក្សកាន់អំណាច និងការធ្វើដោយតំណាងរាស្ត្រគណបក្សប្រឆាំង ត្រូវបានសង្កេតឃើញថាមានសភាពខុសគ្នា ជាពិសេសត្រង់ការអនុញ្ញាតឱ្យមានសំណួរ ឬក៏មិនឱ្យមានសំណួរពីសំណាក់ប្រធានរដ្ឋសភា។ ការកោះហៅរបស់តំណាងរាស្ត្រគណបក្សកាន់អំណាច ត្រូវបានប្រធានរដ្ឋសភាអនុញ្ញាតឱ្យសួរសំណួរទៅតំណាងរាជរដ្ឋាភិបាល នៅខណៈពេលដែលតំណាងរាស្ត្រគណបក្សប្រឆាំងមិនត្រូវបានប្រធានរដ្ឋសភាអនុញ្ញាតឱ្យសួរដេញដោលទៅតំណាងរាជរដ្ឋាភិបាលដែលមកឆ្លើយបំភ្លឺនៅរដ្ឋសភានោះឡើយ។

រដ្ឋសភានីតិកាលទី៤ ការកោះហៅរដ្ឋមន្ត្រីមកឆ្លើយបំភ្លឺផ្ទាល់មាត់ គឺធ្វើឡើងដោយក្រុមអ្នកតំណាងរាស្ត្រគណបក្សប្រឆាំងតែប៉ុណ្ណោះ។ ការមកបំភ្លឺផ្ទាល់មាត់របស់តំណាងរាជរដ្ឋាភិបាលនៅពេលនោះ គឺមិនត្រូវបានប្រធានរដ្ឋសភាបើកឱកាសឱ្យអ្នកតំណាងរាស្ត្រសួរដេញដោលឡើយ សូម្បីតែអានសំណួររបស់ខ្លួនដែលបានបញ្ជូនទៅរាជរដ្ឋាភិបាលក៏មិនត្រូវបានប្រធានរដ្ឋសភាអនុញ្ញាតដែរ។ គួរបញ្ជាក់ថា ក្នុងនីតិកាលទី៤ កន្លងទៅនេះ ក្រុមអ្នកតំណាងរាស្ត្រគណបក្សប្រឆាំងបានកោះហៅរដ្ឋមន្ត្រី និងនាយករដ្ឋមន្ត្រីមកបំភ្លឺដោយផ្ទាល់មាត់នៅក្នុងរដ្ឋសភា។

### ១.១.១ ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំរដ្ឋសភា

ខ្លឹមសារនៃការបញ្ចេញមតិតំណាងរាស្ត្រ និងគោលជំហររបស់តំណាងរាស្ត្រម្នាក់ៗមាននិន្នាការស្របទៅនឹងបន្ទាត់នយោបាយរបស់គណបក្សខ្លួន។ ការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សកាន់អំណាចភាគច្រើន តែងតែបញ្ចេញមតិការពារ ឬក៏កោតសរសើរគាំទ្រនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ គណបក្សប្រឆាំង គឺរិះគោលនយោបារបស់រាជរដ្ឋាភិបាល។

ទោះជាយ៉ាងណា ក្នុងដើមនីតិកាលទី៥នេះ ការបញ្ចេញមតិពិភាក្សារបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានឡើងបញ្ចេញមតិនោះ ភាគច្រើនបញ្ចេញមតិអនុម័តលើសេចក្តីព្រាងច្បាប់/ស្នើច្បាប់មួយចំនួនប៉ុណ្ណោះ ដែលមានការជជែកសាកសួរដេញដោលទៅលើតំណាងរាជរដ្ឋាភិបាល ដែលជាអ្នកការពារសេចក្តីព្រាងច្បាប់ ដែលផ្ទុយពីនីតិកាលទី៤ ដែលការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សកាន់អំណាចភាគច្រើន គឺចេញមុខការពារសេចក្តីព្រាងច្បាប់ជំនួសឱ្យតំណាងរាជរដ្ឋាភិបាលក្នុងពេលពិភាក្សា និងអនុម័ត។

ការសង្កេតជាទូទៅឃើញថា មានតំណាងរាស្ត្រភាគច្រើនដែលមិនបានឡើងបញ្ចេញមតិពិភាក្សាលើច្បាប់ដោយស្ថិតនៅក្នុងស្ថានភាពស្ងប់ស្ងាត់ មិនសូវមានការបញ្ចេញមតិយោបល់ក្នុងការពិភាក្សានោះ មានការលើកឡើងថា ការបញ្ចេញមតិមកវាអាចប៉ះពាល់ដល់ពីតួនាទីរបស់ខ្លួន ប្រសិនការបញ្ចេញមតិខុសផ្ទុយនឹងគោលនយោបាយគណបក្សខ្លួនជាដើម។

### ១.១.២ ការបញ្ចេញមតិជាបរិមាណរបស់អ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំពេញអង្គរដ្ឋសភា

រយៈពេល១ឆ្នាំនេះ មានអ្នកតំណាងរាស្ត្រសរុបចំនួន២៣រូប មកពីគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិដែលមានអាសនៈក្នុងរដ្ឋសភា បានឡើងបញ្ចេញមតិរយៈពេលសរុប៦៩៣នាទី(១១ម៉ោង៣៣នាទី)។ ការបញ្ចេញមតិបើជាមធ្យមក្នុងតំណាងរាស្ត្រ១រូប បានបញ្ចេញមតិបានប្រមាណ៣០នាទី។

តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមានអាសនៈ៦៨ នៅក្នុងរដ្ឋសភា មានតំណាងរាស្ត្រ១៩រូបបានឡើងបញ្ចេញមតិសរុបចំនួន៦៣២នាទី(ស្មើនឹង១០ម៉ោង៣២នាទី)។ រីឯតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិដែលមានអាសនៈ៥៥រូប នៅក្នុងរដ្ឋសភា មានតំណាងរាស្ត្រចំនួន៤រូបបានឡើងបញ្ចេញមតិសរុបចំនួន៦១នាទី(ស្មើនឹង១ម៉ោង១នាទី)។ ការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សសង្គ្រោះ គឺនៅបន្ទាប់ពីតំណាងគណបក្សសង្គ្រោះជាតិសម្រេចចូលរដ្ឋសភា បន្ទាប់ពីមានការចរចាកិច្ចព្រមព្រៀង ស្តីពីដំណោះស្រាយនយោបាយ ដើម្បីបញ្ចប់ភាពជាប់គាំនយោបាយ នៅថ្ងៃទី២២ កក្កដា ២០១៤។

*តួលេខ១៖ចំនួនតំណាងរាស្ត្រ និងរយៈពេលបញ្ចេញមតិតាមគណបក្ស*




ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រគិតជាបរិមាណ ក្នុងសម័យប្រជុំពេញអង្គរដ្ឋសភាសម្រាប់របាយការណ៍ឆ្នាំទី១ នៃរដ្ឋសភានីតិកាលទី៥នេះ ឃើញថាការបញ្ចេញមតិភាគច្រើនគឺធ្វើដោយអ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា។ ដោយឡែកការឡើងបញ្ចេញមតិដោយអ្នកតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិមានតិចតួច ក៏ព្រោះតំណាងរាស្ត្រគណបក្សនេះ សម្រេចចូលរដ្ឋសភានៅចុងឆ្នាំទី១នៃឆ្នាំសង្កេតការណ៍។

តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមានចំនួន១៩រូប ស្មើនឹង២៨%នៃចំនួនតំណាងរាស្ត្រគណបក្សខ្លួនបានបញ្ចេញមតិសរុបចំនួន៦៣២នាទី(ស្មើនឹង៩១%)នៃចំនួនបញ្ចេញមតិសរុប។ តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិមានតំណាងរាស្ត្រ៤រូប (ស្មើនឹង៣%) នៃចំនួនតំណាងរាស្ត្រសរុបក្នុងគណបក្សខ្លួនបញ្ចេញមតិសរុបចំនួន ៦១នាទី (ស្មើនឹង៩%)នៃចំនួនបញ្ចេញមតិសរុបនៅក្នុងរដ្ឋសភា។

### ១.១.៣ ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុប

ខ្លឹមសារមតិរបស់អ្នកតំណាងរាស្ត្រដែលបានបញ្ចេញនៅក្នុងអំឡុងពេលប្រជុំពេញអង្គ ត្រូវបានវិភាគដោយបែងចែកជាបីសូរ(Tone) គឺ៖ អព្យាក្រឹត្យ វិជ្ជមាន និងអវិជ្ជមាន ចំពោះស្ថាប័ន របៀបវារៈ ឬតួអង្គ/ស្ថាប័នរដ្ឋាភិបាលណាមួយដែលអ្នកតំណាងរាស្ត្រនិយាយសំដៅទៅ។ ខ្លឹមសារអព្យាក្រឹត្យ គឺសំដៅលើមតិធម្មតាទៅលើតួអង្គ ឬស្ថាប័នណាមួយ។ ចំណែកឯវិជ្ជមាន គឺផ្តោតលើការលើកសរសើរពីគុណសម្បត្តិសេចក្តីព្រាងច្បាប់គោលនយោបាយ ឬតួអង្គ ឬស្ថាប័នណាមួយ។ រីឯអវិជ្ជមានវិញ គឺនិយាយពីគុណវិបត្តិរបស់តួអង្គ ឬស្ថាប័នណាមួយ។

រយៈពេលរបាយការណ៍នេះ មានតំណាងរាស្ត្រចំនួន២៣រូបនៃចំនួនតំណាងរាស្ត្រសរុបនៅក្នុងរដ្ឋសភា បានបញ្ចេញមតិសរុបចំនួន៦៩៣នាទីស្មើនឹង(១១ម៉ោង៣៣នាទី)នៃរយៈពេលបញ្ចេញមតិសរុប។ ការបញ្ចេញមតិតំណាងរាស្ត្រ ខុមហ្វ្រែលសង្កេតឃើញថា ការបញ្ចេញមតិផ្តោតទៅលើខ្លឹមសារបែបអព្យាក្រឹត្យ និងវិជ្ជមាន ក្នុងនោះខ្លឹមសារបែបអព្យាក្រឹត្យបានចំនួន៥១៥នាទី(ស្មើនឹង៨ម៉ោង៣៥នាទី) និងវិជ្ជមានបានចំនួន១៧៥នាទី(ស្មើនឹង២ម៉ោង៥៥នាទី) ចំណែកខ្លឹមសារអវិជ្ជមានបានចំនួន៣នាទីប៉ុណ្ណោះ។

### ១.១.៤ ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុបតាមគណបក្ស

ខ្លឹមសារការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុបតាមគណបក្ស ការសង្កេតឃើញថា ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រធ្វើឡើងទៅតាមនិន្នាការគណបក្សនយោបាយរបស់ខ្លួន។ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា គឺបានផ្តោតទៅលើខ្លឹមសារបែបអព្យាក្រឹត្យ និងបែបវិជ្ជមាន។ ដោយឡែក តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិវិញ នៅក្នុងរយៈពេលនេះការបញ្ចេញមតិ គឺផ្តោតទៅលើខ្លឹមសារបែបអព្យាក្រឹត្យ។

*តួលេខ ២៖ ចំនួននាទីនិងភាគរយការបញ្ចេញមតិ អព្យាក្រឹត្យ វិជ្ជមាន អវិជ្ជមាន របស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា*




តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបញ្ចេញមតិ ផ្តោតទៅលើខ្លឹមសារអព្យាក្រឹត្យ និងវិជ្ជមាន។ ក្នុងន័យអព្យាក្រឹត្យ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បញ្ចេញមតិចំនួន៤៦៨នាទី ឬ៧ម៉ោង៤៨នាទី(ស្មើនឹង៧៤%) នៃរយៈពេលសរុបរបស់គណបក្សខ្លួន។ ខ្លឹមសារវិជ្ជមាន បញ្ចេញមតិបានចំនួន១៦១នាទី ឬ២ម៉ោង៤១នាទី(ស្មើនឹង២៥%)នៃរយៈពេលសរុបរបស់គណបក្សខ្លួន។ ចំពោះខ្លឹមសារអវិជ្ជមានតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ចំណាយពេល៣នាទី ស្មើនឹង១% នៃរយៈពេលសរុបរបស់គណបក្សខ្លួន។

*តួលេខ៣៖ ចំនួននាទី និងភាគរយការបញ្ចេញមតិ អព្យាក្រឹត្យ វិជ្ជមាន អវិជ្ជមាន របស់អ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ*

តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ គឺបញ្ចេញមតិផ្តោតទៅលើខ្លឹមសារអព្យាក្រឹត្យតែប៉ុណ្ណោះ។ ដោយខ្លឹមសារបែបអព្យាក្រឹត្យចំណាយពេល៤៧នាទី(ស្មើនឹង៧៧%) នៃរយៈពេលគណបក្សខ្លួនសរុប។ ខ្លឹមសារបែបវិជ្ជមាន តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិចំណាយពេល១៤នាទី (ស្មើនឹង២៣%)នៃរយៈពេលបញ្ចេញមតិសរុបរបស់បក្សខ្លួន។




### ១.១.៥ ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រតាមគណបក្សទៅលើតួអង្គស្ថាប័ន និងចំណុចផ្សេងៗ

តារាងខាងក្រោមនេះ បានបង្ហាញពីខ្លឹមសារការបញ្ចេញមតិរបស់តំណាងរាស្ត្រតាមគណបក្ស ទៅលើតួអង្គ ឬស្ថាប័ននានានៅក្នុងសម័យប្រជុំពេញអង្គទាំង២០កិច្ចប្រជុំ។ អ្នកតំណាងរាស្ត្របានបញ្ចេញមតិក្នុងខ្លឹមសារបែបអព្យាក្រឹត្យ អវិជ្ជមាន និងវិជ្ជមាន។

*តារាងទី១៖គុណភាពការបញ្ចេញមតិរបស់ តំណាងរាស្ត្រតាមគណបក្សនយោបាយទាំងបីចំណុចសំខាន់ៗមួយចំនួន (គិតជានាទី)*

| ល.រ | ចំណុចដែលពាក់ព័ន្ធ | គណបក្សសង្គ្រោះជាតិ | | | គណបក្សប្រជាជនកម្ពុជា | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | អព្យាក្រឹត្យ | វិជ្ជមាន | អវិជ្ជមាន | អព្យាក្រឹត្យ | វិជ្ជមាន | អវិជ្ជមាន | |
| ១ | របៀបវារៈកំពុងពិភាក្សា | ៨ | ១៤ | ០ | ៤៥ | ១១៧ | ០ | ១៨៤ |
| ២ | នាយករដ្ឋមន្ត្រី | ១ | ០ | ០ | ៤៣ | ៨ | ០ | ៥២ |
| ៣ | រាជរដ្ឋាភិបាល | ២ | ០ | ០ | ៨៥ | ១៤ | ០ | ១០១ |
| ៤ | ប្រធានរដ្ឋសភា | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ៥ | រដ្ឋសភា | ០ | ០ | ០ | ០ | ០ | ០ | ៥ |
| ៦ | គណៈកម្មការនានារបស់រដ្ឋសភា | ០ | ០ | ០ | ០ | ៨ | ០ | ១៩ |
| ៧ | ប្រធានព្រឹទ្ធសភា | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ៨ | ស្ថាប័នព្រឹទ្ធសភា និងសមាជិក | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ៩ | គណបក្សខ្លួនគាត់ | ០ | ០ | ០ | ៦ | ០ | ០ | ៦ |
| ១០ | គណបក្សដទៃទៀត | ៣ | ០ | ០ | ៦ | ០ | ០ | ៩ |
| ១១ | តំណាងរាស្ត្រខ្លួនឯង | ៤ | ០ | ០ | ៣០ | ៣ | ០ | ៣៧ |
| ១២ | តំណាងរាស្ត្រដទៃទៀត | ១ | ០ | ០ | ៦ | ០ | ០ | ៧ |
| ១៣ | មណ្ឌល (ខេត្ត/រាជធានី)របស់គាត់ | ០ | ០ | ០ | ២ | ០ | ០ | ២ |
| ១៤ | មណ្ឌល (ខេត្ត/រាជធានី)ផ្សេងទៀត | ០ | ០ | ០ | ១ | ០ | ០ | ១ |
| ១៥ | តុលាការ | ០ | ០ | ០ | ៦ | ២ | ៣ | ៨ |
| ១៦ | បញ្ហាស្ត្រី | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ១៧ | អនុសាសន៍លើច្បាប់កំពុងពិភាក្សា | ២៨ | ០ | ០ | ១៩៩ | ៩ | ០ | ២៣៦ |
| ១៨ | សំណួរ/សុំការបំភ្លឺលើច្បាប់កំពុង... | ០ | ០ | ០ | ១៣ | ០ | ០ | ១៣ |
| ១៩ | យុវជន | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ២០ | បញ្ហាផ្សេងៗ | ០ | ០ | ០ | ១០ | ០ | ០ | ១០ |
| | | ៦១ | | | ៦៣២ | | | ៦៩៣ |

ក្នុងរយៈពេលនេះ ការសង្កេតឃើញថា ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រនៃគណបក្សនយោបាយទាំងពីរផ្តោតសំខាន់ទៅលើចំណុចពាក់ព័ន្ធចំនួន៣ ដោយត្រូវបានចំណាយរយៈពេលច្រើនជាងគេ ក្នុងចំណោមតួអង្គ

និងស្ថាប័នទាំង២០។ ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្របានផ្តោតខ្លាំងទៅលើ ការផ្តល់ជាអនុសាសន៍លើច្បាប់កំពុងពិភាក្សា របៀបវារៈកំពុងពិភាក្សា និងតួអង្គរាជរដ្ឋាភិបាល ដែលត្រូវបានក្រុមអ្នកតំណាងរាស្ត្រចំណាយរយៈពេលបញ្ចេញមតិសរុប៥២១នាទី ឬ៨ម៉ោង៤១នាទី(ស្មើនឹង៧៥%)នៃរយៈពេលអ្នកតំណាងរាស្ត្របញ្ចេញមតិសរុប។

ការបញ្ចេញមតិរបស់តំណាងរាស្ត្រដោយផ្តោតលើអនុសាសន៍ចំពោះសេចក្តីព្រាងច្បាប់ ដែលកំពុងពិភាក្សា គឺសំដៅទៅលើការយកទៅអនុវត្តរបស់រដ្ឋាភិបាល ត្រូវបានអ្នកតំណាងរាស្ត្រចំណាយរយៈពេលអស់២៣៦នាទី ឬ៣ម៉ោង៥៦នាទី (ស្មើនឹង៣៤%)នៃចំនួនរយៈពេលតំណាងរាស្ត្របញ្ចេញមតិសរុប។ ចំពោះចំណុចពាក់ព័ន្ធលើរបៀបវារៈកំពុងពិភាក្សា ត្រូវបានអ្នកតំណាងរាស្ត្រចំណាយពេលបញ្ចេញមតិអស់១៨៤នាទី ឬ៣ម៉ោង៤០នាទី(ស្មើនឹង២៧%)នៃរយៈពេលតំណាងរាស្ត្របញ្ចេញមតិសរុប។ ចំណុចដែលពាក់ព័ន្ធនឹងរាជរដ្ឋាភិបាលដែលសំដៅទៅលើតួអង្គរាជរដ្ឋាភិបាល ឬស្ថាប័នរដ្ឋាភិបាល ត្រូវបានតំណាងរាស្ត្រចំណាយរយៈពេលបញ្ចេញមតិអស់១០១នាទី១ម៉ោង៤១នាទី(ស្មើនឹង១៥%) នៃរយៈពេលអ្នកតំណាងរាស្ត្របញ្ចេញមតិសរុប។

ចំពោះខ្លឹមសារនៃការបញ្ចេញមតិរបស់តំណាងរាស្ត្រក្នុងដើមនីតិកាលទី៥នេះ គឺផ្តោតទៅលើខ្លឹមសារបែបវិជ្ជមាន និងអព្យាក្រឹត្យតែប៉ុណ្ណោះ។

ការបញ្ចេញមតិរបស់តំណាងរាស្ត្រ ជុំវិញការផ្តល់អនុសាសន៍លើសេចក្តីព្រាងច្បាប់កំពុងពិភាក្សា តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានបញ្ចេញមតិ ក្នុងន័យអព្យាក្រឹត្យចំនួន១៩៩នាទីស្មើនឹង៣ម៉ោង១៩នាទី ហើយតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិបញ្ចេញមតិបានចំនួន២៨នាទី។ ចំណែកការបញ្ចេញមតិទៅលើរបៀបវារៈកំពុងពិភាក្សា តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានបញ្ចេញមតិក្នុងន័យវិជ្ជមានបានចំនួន១១៧នាទី ១ម៉ោង៥៧នាទី ហើយតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិបញ្ចេញមតិក្នុងន័យវិជ្ជមានបានចំនួន១៤នាទី។ ចំពោះចំណុចពាក់ព័ន្ធនឹងស្ថាប័នរាជរដ្ឋាភិបាល ត្រូវបានតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបញ្ចេញមតិ ផ្តោតទៅលើខ្លឹមសារអព្យាក្រឹត្យបានចំនួន ៨៥នាទីស្មើនឹង១ម៉ោង៣៥នាទី និងតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិបានបញ្ចេញមតិក្នុងន័យអព្យាក្រឹត្យបានចំនួន២នាទី។

### ១.១.៦ គុណភាពនៃការពិភាក្សា និងអនុម័តរបៀបវារៈ

ក្នុងសម័យប្រជុំសភា លើកទី១ និងលើកទី២ ចន្លោះពីខែកញ្ញា ២០១៣ ដល់តុលា ២០១៤ នេះ រដ្ឋសភាបានបើកសម័យប្រជុំចំនួន១១ដង ដោយបានដំណើរការកិច្ចប្រជុំចំនួន២០កិច្ចប្រជុំ ដែលក្នុង១កិច្ចប្រជុំ រដ្ឋសភាប្រើប្រាស់ត្រឹមតែ១ព្រឹកប៉ុណ្ណោះ។

ក្នុងរយៈពេលនេះ រដ្ឋសភាមានរបៀបវារៈសរុបចំនួន៣៦របៀបវារៈ ដែលក្នុងនោះពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ចំនួន៣០ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំនួន៣ និងការឆ្លើយបំភ្លឺផ្ទាល់មាត់ពីតំណាងរាជរដ្ឋាភិបាលចំនួន១ ចំណែករបៀបវារៈ២ផ្សេងទៀត គឺព្រះរាជសាររព្រះករុណាបើកសម័យប្រជុំ និងរបាយការណ៍ស្តីពី

សកម្មភាពសភាចន្លោះសម័យប្រជុំពេញអង្គ។ ដោយឡែក ក្នុងកិច្ចប្រជុំពេញអង្គវិសាមញ្ញវិញមានរបៀបវារៈចំនួន៥ រួមមាន ទី១. ការប្រកាសសុពលភាពនៃអណត្តិរបស់ឯកឧត្តម សម រង្ស៊ី ទី២. សេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មប្រការ៦ថ្មីនៃបទបញ្ជាផ្ទៃក្នុង និងរបៀបវារៈ៣ទៀត គឺជាបោះឆ្នោតជ្រើសតាំងអនុប្រធានទី១ អនុប្រធានទី២ និងបោះឆ្នោតជ្រើសតាំងជំនួស និងបំពេញបន្ថែមសមាជិកគណៈកម្មការជំនាញនៃរដ្ឋសភា។

ក្នុងរបៀបវារៈដែលត្រូវបានយកមកពិភាក្សា និងអនុម័តនោះមាន សេចក្តីព្រាងច្បាប់ចំនួន១៤ ការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងចំនួន១៤ និងវិសោធនកម្មច្បាប់ចំនួន៣(នៅក្នុងសម័យប្រជុំពេញអង្គជាវិសាមញ្ញ)។

ឆ្នាំសង្កេតនេះ ខុមហ្វ្រែលសង្កេតឃើញថា ក្នុង១របៀបវារៈ រដ្ឋសភាបានប្រើរយៈពេលត្រឹមតែ១កិច្ចប្រជុំប៉ុណ្ណោះ (១ព្រឹក)ក្នុងការពិភាក្សា និងអនុម័ត។ មានសេចក្តីព្រាងច្បាប់/សេចក្តីស្នើច្បាប់ ឬក៏កិច្ចព្រមព្រៀងមួយចំនួនត្រូវបានរដ្ឋសភាយកមកអនុម័តតែម្តង ដោយមិនមានការពិភាក្សា ឬក៏ជជែកសួរដេញដោលនោះទេ។

រាល់ច្បាប់ក្នុងកិច្ចប្រជុំរដ្ឋសភាដែលមិនមានការពិភាក្សា អ្នកតំណាងរាស្ត្រគណបក្សកាន់អំណាចតែងតែលើកឡើងបញ្ជាក់លើច្បាប់នេះ ត្រូវបានពិភាក្សា និងបានសួរដេញដោលយ៉ាងលំអិត នៅក្នុងគណៈកម្មការជំនាញមុននឹងដាក់ជូនកិច្ចប្រជុំពេញអង្គរដ្ឋសភារួចមកហើយ។

### ១.១.៧ សេចក្តីព្រាងច្បាប់សំខាន់ៗត្រូវបានអនុម័ត ហើយបន្សល់នូវភាពចម្រូងចម្រាស

ឆ្នាំនេះសេចក្តីព្រាងច្បាប់ចំនួន៣ដែលរដ្ឋសភាអនុម័តរួច ទាក់ទងវិស័យតុលាការ ហើយនៅខណៈដែលមិនមានការចូលរួមពីក្រុមតំណាងរាស្ត្រគណបក្សប្រឆាំង។ សេចក្តីព្រាងច្បាប់ទាំងបី ត្រូវបានក្រុមអង្គការសង្គមស៊ីវិលមួយចំនួនព្រួយបារម្ភ និងស្នើសុំឲ្យសភា(រដ្ឋសភា និងព្រឹទ្ធសភា) ផ្អាកការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ទាំងនោះ។

សេចក្តីព្រាងច្បាប់ទាំង៣នោះ ត្រូវបានក្រុមអង្គការសង្គមស៊ីវិលមួយចំនួនបានរិះគន់ដល់រាជរដ្ឋាភិបាលពុំបានផ្សព្វផ្សាយគ្រប់គ្រាន់ និងបើកឱ្យសាធារណជនបានពិនិត្យ និងចូលរួមផ្តល់យោបល់មុននឹងបញ្ជូនទៅដល់រដ្ឋសភាពិភាក្សា និងអនុម័ត។

តាមសេចក្តីថ្លែងការណ៍របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានអំពាវនាវឲ្យសភាផ្អាកក្នុងការអនុម័តលើសេចក្តីព្រាងច្បាប់ទាំងនេះ លុះណាតែមានការផ្សព្វផ្សាយ និងបើកឲ្យមានកិច្ចពិគ្រោះយោបល់ទូលំទូលាយជាមុន និងព្រមទាំងរហូតដល់អ្នកតំណាងរាស្ត្រមកពីគណបក្សជាប់ឆ្នោតទាំង២ចូលអង្គុយក្នុងរដ្ឋសភា។

ច្បាប់ទាំង៣នោះមានៈ សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការដែលមាន ៨ជំពូកចែងជា៩១មាត្រា, សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមាន ៦ជំពូកចែងជា៣១មាត្រា និងសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលមាន៦ជំពូកចែងជា១១១មាត្រា។

តបទៅនឹងក្រុមសង្គមស៊ីវិលរិះគន់ពីសាធារណជន អ្នកតំណាងរាស្ត្រ ជាម យៀប មន្ត្រីជាន់ខ្ពស់របស់គណបក្សប្រជាជនកម្ពុជា បានចេញមុខការពារថា រដ្ឋសភាបច្ចុប្បន្នមានបទពិសោធន៍ និងមានចំណេះដឹងគ្រប់គ្រាន់ក្នុងការពិនិត្យលើសេចក្តីព្រាងច្បាប់ទាំងបីនេះ៖ «*ពីព្រោះអ្នក៦៨នាក់នេះ នៅក្នុងរដ្ឋសភា ៣០ឆ្នាំហើយ យើងអាចមានលទ្ធភាពយល់អំពីច្បាប់ច្រើនណាស់ទៅហើយ។ តំណាងរាស្ត្រមួយចំនួនធំទៀត លោកមានអតីតកាលបទពិសោធន៍ច្រើន មេរៀនគ្រប់បែបយ៉ាងយល់ពីសភាពការណ៍កម្ពុជាគ្រប់បែបយ៉ាងតែម្តង*»។ ផ្ទុយទៅវិញអ្នក ឃ្លាំមើលមានការព្រួយបារម្ភថា សេចក្តីព្រាងច្បាប់នឹងមិនត្រូវបានពិនិត្យពិច័យឲ្យបានគ្រប់ជ្រុងជ្រោយ និងមិនបានឆ្លុះបញ្ចាំងឆន្ទៈរបស់ប្រជាពលរដ្ឋទាំងស្រុងនោះទេ ដោយហេតុថា ក្នុងរដ្ឋសភាមានតំណាងរាស្ត្រតែពីមួយគណបក្ស ហើយជាគណបក្សដឹកនាំស្ថាប័ននីតិប្រតិបត្តិ ដែលជាអ្នករៀបចំសេចក្តីព្រាងច្បាប់ទាំងនេះ។

ជុំវិញបញ្ហានេះលោក សុក សំអឿន ជាប្រធានការិយាល័យក្រុមអ្នកច្បាប់អមរិន្ទ្របានមានប្រសាសន៍ថា សេចក្តីព្រាងច្បាប់ទាំងបីនោះមានចំណុចល្អ និងមិនច្បាស់លាស់មួយចំនួន៖ «*យើងឃើញមានបញ្ហា គឺថាច្បាប់នេះអោយអំណាចទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ខ្លាំងពេក។ យើងមើលទៅការងារ គឺនៅក្រោមដៃរដ្ឋមន្ត្រីក្រសួងយុត្តិធម៌តែម្តង។ មានចំណុច២ ដែលមើលទៅឃើញក្រោមក្រសួងយុត្តិធម៌ គឺទី១ អគ្គលេខាធិការដ្ឋានគឺនៅក្រោមក្រសួងយុត្តិធម៌ និងទី២ ក្រុមអធិការកិច្ច ក៏ចាត់ចែងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដូចគ្នា*»។

### ១.២ ការប្រជុំរបស់គណៈកម្មការជំនាញ/ប្រជុំដេញដោល ឬការឆ្លើយបំភ្លឺ

រដ្ឋសភាជាតិនីតិកាលទី៥នេះ មានគណៈកម្មការជំនាញចំនួន១០ ដែលក្នុងមានគណៈកម្មការមួយទើបនឹងបង្កើតថ្មី គឺគណៈកម្មការទី១០ "គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយដោយបែកចេញពីគណៈកម្មការទី៤ ហើយប្តូរឈ្មោះទៅជាគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ។

ក្នុងរយៈពេលនេះ គណៈកម្មការជំនាញដែលគណបក្សប្រជាជនកម្ពុជាធ្វើជាប្រធាន និងជាលេខាធិការនោះ រួមមាន គណៈកម្មការទី២ គណៈកម្មការទី៤ គណៈកម្មការទី៥ គណៈកម្មការទី៦ និងគណៈកម្មការទី៩។ ចំណែកគណៈកម្មការជំនាញដែលគណបក្សសង្គ្រោះជាតិធ្វើជាប្រធាន និងជាលេខាធិការ រួមមានដូចជា គណៈកម្មការទី១ គណៈកម្មការទី៣ គណៈកម្មការទី៧ គណៈកម្មការទី៨ និងគណៈកម្មការទី១០។

គួរបញ្ជាក់ថា គណៈកម្មការជំនាញរដ្ឋសភាដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ខុមហ្វ្រែលមិនសូវទទួលបានព័ត៌មានអំពីសកម្មភាពការងាររបស់គណៈកម្មការជំនាញទាំងនោះទេ។ សកម្មភាពការងាររបស់គណៈកម្មការជំនាញទាំងនោះ ខុមហ្វ្រែលទទួលព័ត៌មានតែតាមរយៈរបាយការណ៍សង្ខេប ស្តីពីសកម្មភាពរបស់រដ្ឋសភាចន្លោះសម័យប្រជុំរដ្ឋសភាប៉ុណ្ណោះ។

បន្ទាប់ពីមានការបែងចែកអំណាចក្នុងរដ្ឋសភា រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ការសង្កេតឃើញថា គណៈកម្មការជំនាញរដ្ឋសភាមួយចំនួនធំ ដែលដឹកនាំដោយតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិបានធ្វើសកម្មភាពសកម្មជាងឆ្នាំសង្កេតមុន ដោយមានការកោះហៅរដ្ឋមន្ត្រីមកបំភ្លឺក្នុងគណៈកម្មការជំនាញ

សកម្មភាពទទួលពាក្យបណ្ដឹងពីប្រជាពលរដ្ឋ និងការអនុញ្ញាតឱ្យប្រជាពលរដ្ឋដែលមានទំនាស់(ដីធ្លី) បានជួបពិភាក្សា បង្ហាញពីបញ្ហា និងតម្រូវការរបស់ពួកគេនៅក្នុងគណៈកម្មការជំនាញ។ សកម្មភាពបែបនេះអាចបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថា រដ្ឋសភាជាតិមានការផ្លាស់ប្ដូរឥរិយាបទក្នុងការបំពេញតួនាទីភារកិច្ចការងាររបស់ខ្លួន បន្ទាប់ពីមានការចូលរួមក្នុងរចនាសម្ព័ន្ធដឹកនាំរបស់រដ្ឋសភានីតិកាលទី៥នេះ។

ការសង្កេតឃើញថា គណៈកម្មការជំនាញដែលដឹកនាំដោយគណបក្សសង្គ្រោះជាតិបានធ្វើសកម្មភាពការងារច្រើនជាងគណៈកម្មការជំនាញដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ពិសេសកម្មភាពការកោះហៅរដ្ឋមន្ត្រីមកបំភ្លឺនៅក្នុងគណៈកម្មការជំនាញ និងការចេញមកទទួលយកញាត្តិពីប្រជាពលរដ្ឋ ការចុះពិនិត្យ និងដោះស្រាយករណីទំនាស់នានា (ទំនាស់ដីធ្លី) របស់ប្រជាពលរដ្ឋ។

ក្នុងរយៈពេលនេះ ការសង្កេតឃើញថា មានរដ្ឋមន្ត្រីចំនួន៤រូប រួមមានដូចជា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានហៅមកបំភ្លឺដោយផ្ទាល់មាត់នៅក្នុងគណៈកម្មការជំនាញរដ្ឋសភា។

គណៈកម្មការជំនាញទី៧នៃរដ្ឋសភា ដឹកនាំដោយអ្នកតំណាងរាស្ត្រ យ៉ែម បុញ្ញឫទ្ធិ មកពីគណបក្សសង្គ្រោះជាតិបានអញ្ជើញរដ្ឋមន្ត្រីចំនួន២រូបមកបំភ្លឺផ្ទាល់មាត់នៅក្នុងរដ្ឋសភា ដូចជាលោក ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងលោក មិន ឃិន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា។ ដោយឡែកគណៈកម្មការជំនាញទី៨នៃរដ្ឋសភា បានអញ្ជើញលោក ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមកបំភ្លឺដោយផ្ទាល់មាត់នៅក្នុងគណៈកម្មការជំនាញរដ្ឋសភា។ ជាក់ស្តែង កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៤ លោកស្រី កែ សុវណ្ណរតន៍ ប្រធានគណៈកម្មការទី៨ នៃរដ្ឋសភា បានជួបពទល់គ្នាជាមួយរដ្ឋមន្ត្រីក្រសួងសុខាភិបាលលោក ម៉ម ប៊ុនហេង ពិភាក្សាអំពីបញ្ហាមួយចំនួនដែលជាក្តីកង្វល់របស់ប្រជាពលរដ្ឋទាក់ទងនឹងប្រព័ន្ធសុខាភិបាលបច្ចុប្បន្ន។

ទន្ទឹមនឹងនេះ ប្រធានគណៈកម្មការទី១ និងទី១០ នៃរដ្ឋសភា ដែលដឹកនាំដោយតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ ក៏បានធ្វើសកម្មភាពគួរឱ្យកត់សម្គាល់ដែរ។ គណៈកម្មការទី១ ដឹកនាំដោយលោក អេង ឆៃអ៊ាង បានកោះហៅតំណាងប្រជាពលរដ្ឋ និងតំណាងក្រុមហ៊ុនខេឌីស៊ីរបស់ លោកស្រីជា ខេង ក្នុងករណីទំនាស់ដីធ្លីនៅសហគមន៍ឡពាង ខេត្តកំពង់ឆ្នាំង ដើម្បីពិភាក្សារកដំណោះស្រាយ។ រីឯគណៈកម្មការទី១០ វិញ លោក ហូរ វ៉ាន់ បានកោះហៅប្រធានអង្គភាពប្រឆាំងអំពើពុករលួយលោក ឱម យ៉ិនទៀង និងនាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា លោក ព្រាប កុល មកសាកសួរជុំវិញអំពើពុករលួយក្នុងប្រទេសកម្ពុជា។

ដោយឡែក គណៈកម្មការជំនាញដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ការសង្កេតមិនឃើញមានសកម្មភាពទាំងនេះទេ។

## II. ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ

រដ្ឋធម្មនុញ្ញមាត្រា៧៧បានកំណត់ថា តំណាងរាស្ត្រក្នុងរដ្ឋសភាជាតំណាងប្រជាជាតិខ្មែរទាំងមូលពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ។ មាត្រា៨៣ ក៏បានកំណត់ដែរថា រដ្ឋសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ ដោយសម័យប្រជុំមួយដងមានថិរៈវេលាយ៉ាងតិចបីខែ។ មាត្រា៨៨ បានកំណត់ដែរថា រដ្ឋសភាជាតិប្រជុំជាសាមញ្ញចំនួនពីរដងក្នុងមួយឆ្នាំ ដោយសម័យប្រជុំមួយដងមានថិរៈវេលាយ៉ាងតិចបីខែ ដូច្នេះក្នុងចន្លោះសម័យប្រជុំដែលជារយៈពេលរដ្ឋសភាវិស្សមកាល ដែលអាចអោយអ្នកតំណាងរាស្ត្របានយកពេលនោះចុះមូលដ្ឋានដើម្បីជួប និងដោះស្រាយបញ្ហានានារបស់ម្ចាស់ឆ្នោត។

តាមទិន្នន័យដែលអ្នកសង្កេតការណ៍ខុមហ្វ្រែលទទួលបានអំពីសកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ តាមរយៈការចុះសង្កេតដោយផ្ទាល់ ប្រព័ន្ធផ្សព្វផ្សាយ ការិយាល័យតំណាងរាស្ត្រតាមបណ្តាខេត្ត និងតាមរយៈស្នាក់ការគណបក្សនយោបាយនៅតាមបណ្តាខេត្តឃើញថា ក្នុងរយៈពេលពីខែកញ្ញា ២០១៣ ដល់ខែតុលា ២០១៤ មានតំណាងរាស្ត្រចំនួន៩៦រូប ក្នុងចំណោមតំណាងរាស្ត្រ១២៣រូប បានចុះមូលដ្ឋាន ចំនួន១២៧៤លើក។

តាមការសង្កេត ការចុះមូលដ្ឋានតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ បានចុះមូលដ្ឋានច្រើនជាងតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា។ តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិបានចុះមូលដ្ឋានចំនួន៦៦៥លើក ហើយតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាចុះបានចំនួន៦១០លើក។

គ្រប់សកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ គឺបានធ្វើឡើងក្នុងគោលបំណងសំខាន់ៗចំនួន៥ រួមមានៈការចុះសំណេះសំណាលសួរសុខទុក្ខចែកអំណោយជូនប្រជាពលរដ្ឋ និងសម្ពោធសមិទ្ធិផលនានា ការចុះពង្រឹងបណ្តាញផ្ទៃក្នុងគណបក្ស ការចូលរួមវេទិកាសាធារណៈ ការអមដំណើរថ្នាក់ដឹកនាំ និងគោលបំណងចុះជួយអន្តរាគមន៍ដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ដែលមានអាសនៈ៦៨ក្នុងរដ្ឋសភា ខុមហ្វ្រែលទទួលព័ត៌មាន មានតំណាងរាស្ត្រចំនួន៥០រូបបានចុះមូលដ្ឋានបានចំនួន៦១០លើក។ ដែលគិតជាមធ្យមតំណាងរាស្ត្រ១រូប ក្នុងចំណោមតំណាងរាស្ត្រទាំង៥០រូបចុះបានចំនួន១២លើក។ រាល់ការធ្វើសកម្មភាពនៅតាមមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា គឺបានផ្តោតទៅលើគោលបំណងចុះសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋ និងរួមទាំងសម្ពោធសមិទ្ធិផលនានាចំនួន៣៥៩លើក ការអមដំណើរថ្នាក់ដឹកនាំបានចំនួន១៦៨លើក ការចុះពង្រឹងបណ្តាញផ្ទៃក្នុងគណបក្សបានចំនួន៥៧លើក ការចូលរួមវេទិកាសាធារណៈចំនួន៥លើក និងអន្តរាគមន៍ដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋចំនួន២១លើក។

គណបក្សសង្គ្រោះជាតិដែលមាន៥៥អាសនៈក្នុងរដ្ឋសភា មានតំណាងរាស្ត្រចំនួន៤៦រូប បានចុះធ្វើសកម្មភាពក្នុងមូលដ្ឋានរបស់ខ្លួនសរុបចំនួន៦៦៤លើក។ បើគិតជាមធ្យមតំណាងរាស្ត្រ១រូបក្នុងចំណោម៤៦រូប បានធ្វើ

សកម្មភាពក្នុងមូលដ្ឋានចំនួន១៤លើក។ រាល់សកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ បានផ្តោលលើគោលបំណងសំខាន់ៗដូចជា ការចុះសំណេះសំណាលសួរសុខទុក្ខ និងចែកអំណោយដល់ប្រជាពលរដ្ឋចំនួន៣៤៨លើក ការចុះពង្រឹងបណ្តាញផ្ទៃក្នុងគណបក្សចំនួន២០៩លើក ការអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួនចំនួន៧៧លើក អន្តរាគមន៍ដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋចំនួន២៧លើក និងគោលបំណងចូលរួមវេទិកាសាធារណៈចំនួន៣លើក។

## ២.១ ចំនួនដង និងចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋាន

ក្នុងរយៈពេលនៃរបាយការណ៍នេះ ខុមហ្វ្រែលការសង្កេតឃើញថា មានតំណាងរាស្ត្រចំនួន៩៦រូប ក្នុងចំណោមតំណាងរាស្ត្រសរុបចំនួន១២៣រូប បានធ្វើសកម្មភាពចុះមូលដ្ឋានសរុបចំនួន១២៧៤លើក។

*តួលេខ២៤៖ ចំនួនតំណាងរាស្ត្រតាមគណបក្សចុះមូលដ្ឋានធៀបនឹងចំនួនតំណាងចុះមូលដ្ឋានសរុប*

មើលពីចំនួនតំណាងរាស្ត្រតាមគណបក្សចុះមូលដ្ឋានធៀបនឹងចំនួនតំណាងរាស្ត្រចុះមូលដ្ឋានសរុប ខុមហ្វ្រែលឃើញថា ចំនួនតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ចុះមូលដ្ឋានច្រើនជាងចំនួនតំណាងរាស្ត្រតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ។ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា មានចំនួន៥០រូបស្មើនឹង៥២%នៃចំនួនតំណាងរាស្ត្រ ដែលបានចុះមូលដ្ឋានសរុប។ គណបក្សសង្គ្រោះជាតិចំនួន៤៦រូប ស្មើនឹង៤៨%នៃចំនួន តំណាងរាស្ត្រដែលបានចុះមូលដ្ឋានសរុប។




*តួលេខ២៥៖ភាគរយនៃអាសនៈរដ្ឋសភា និងចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋានសរុបតាមគណបក្ស*




គណបក្សប្រជាជនកម្ពុជា មានអាសនៈ៦៨រូបនៅក្នុងរដ្ឋសភា ស្មើនឹង៥៥%នៃចំនួនអាសនៈសរុបក្នុងរយៈពេលរបាយការណ៍គណបក្សប្រជាជនកម្ពុជាមានតំណាងរាស្ត្រចំនួន៥០រូបស្មើនឹង៥២%បានចុះមូលដ្ឋាន។ គណបក្សសង្គ្រោះមាន៥៥អាសនៈមានតំណាងរាស្ត្រ៤៦រូប (ស្មើនឹង៤៧%)នៃចំនួនតំណាងរាស្ត្ររបស់គណបក្សខ្លួនបានចុះមូលដ្ឋានសរុប។

*<u>តួលេខ២៦៖ភាគរយតំណាងរាស្ត្រចុះមូលដ្ឋានធៀបទៅនឹងចំនួនតំណាងរាស្ត្រសរុបក្នុងគណបក្សរបស់ខ្លួន</u>*

ភាគរយតំណាងរាស្ត្រចុះមូលដ្ឋានធៀបទៅនឹងចំនួនតំណាងរាស្ត្រសរុបក្នុងបក្ស បានបង្ហាញឲ្យឃើញថា គណបក្សប្រជាជនកម្ពុជា មានតំណាងរាស្ត្រចំនួន ៧២%បានចុះធ្វើសកម្មភាពតាមមូលដ្ឋាន និងចំនួន ២៨%ទៀត ខុមប្រែ្ហលមិនទទួលបានសកម្មភាពពីការចុះមូលដ្ឋាននោះទេ។ ចំណែកការចុះមូលដ្ឋានរបស់គណបក្សសង្គ្រោះជាតិ ក្នុងឆ្នាំសង្កេតនេះ មានតំណាងរាស្ត្រចុះមូលដ្ឋានបានចំនួន៨៣% ចំណែក១៧%ទៀតដែលមិនបានចុះមូលដ្ឋាននោះ ខាងខុមប្រែ្ហលនៅតែមិនទទួលព័ត៌មានពីការចុះមូលដ្ឋាននោះទេ។




*<u>តួលេខ២៧៖ ចំនួននៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រសរុបតាមគណបក្ស</u>*




បើមើលពីចំនួនចុះមូលដ្ឋានរបស់តំណាងរាស្ត្រសរុបទៅតាមគណបក្សខ្លួនដែលមានអាសនៈនៅក្នុងរដ្ឋសភា ខុមប្រែ្ហលសង្កេតឃើញថា ចំនួនអ្នកតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា ចុះធ្វើសកម្មភាពក្នុងមូលដ្ឋានច្រើនជាងចំនួនតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ។ តែបើមើលចំនួននៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមមូលដ្ឋានវិញ បង្ហាញឱ្យឃើញថា ចំនួនការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិមានចំនួនច្រើនជាង តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា។ តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិធ្វើសកម្មភាពចំនួន៦៥៤លើក រីឯតំណាងរាស្ត្រមកពីគណបក្សប្រជាជនធ្វើសកម្មភាពចំនួន៦១០លើក។

## ២.២ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ

ការធ្វើសកម្មភាពក្នុងមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រត្រូវបានបែងចែកជា៥គោលបំណងគឺ ១. ចុះសួរសុខទុក្ខចែកអំណោយសម្ពោធសមិទ្ធផលនានា (សួរសុខទុក្ខ) ២. ការចុះមូលដ្ឋានដើម្បីពង្រឹងបណ្តាញគណបក្ស (ពង្រឹងគណបក្ស) ៣.ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ(អមដំណើរ) ៤. ការចូលរួមវេទិកា/សិក្ខាសាលាសាធារណៈ(វេទិកា) និង៥.ចុះជួយអន្តរាគមន៍ និងដោះស្រាយបញ្ហានានា (អន្តរាគមន៍)។

*តួលេខ៥៖ភាគរយនៃគោលបំណងនីមួយៗរបស់អ្នកតំណាងរាស្ត្រតាមគណបក្សធៀបនឹងគោលបំណងសរុបតាមគណបក្ស*




ភាគរយនៃគោលបំណងនីមួយៗរបស់តំណាងរាស្ត្រ ទៅតាមគណបក្សរបស់ខ្លួន ធៀបទៅនឹងគោលបំណងសរុបតាមបក្ស ការសង្កេតឃើញថា គោលបំណងចំនួន២ ដែលតំណាងរាស្ត្រទាំង២គណបក្សបានផ្តោតស្មើគ្នា គឺគោលបំណងចុះអន្តរាគមន៍ និងគោលបំណងចូលរួមវេទិកាសាធារណៈ។ តំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជា គឺបានផ្តោតខ្លាំងទៅលើ គោលបំណងចុះសំណេះសំណាលសួរសុខទុក្ខចែកអំណោយសម្ពោធសមិទ្ធផលនានាបាន៥៨%នៃចំនួនចុះមូលដ្ឋានសរុបរបស់គណបក្សខ្លួន។ ការចុះអមដំណើរថ្នាក់ដឹកនាំចំនួន២៨% ការពង្រឹងបណ្តាញផ្ទៃក្នុងគណបក្សចំនួន៩% ចូលរួមវេទិកាចំនួន១% និងការចុះអន្តរាគមន៍ចំនួន៥%។ ចំណែកឯតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិវិញ បានផ្តោតខ្លាំងក្នុងគោលបំណងដូចនឹងតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាផងដែរ គឺការចុះសំណេះសំណាលសួរសុខទុក្ខចែកអំណោយជូនប្រជាពលរដ្ឋចំនួន៥២%នៃចំនួនចុះមូលដ្ឋានសរុបរបស់គណបក្សខ្លួន។ ការចុះពង្រឹងបណ្តាញផ្ទៃក្នុងកណបក្សចំនួន៣១% អមដំណើរថ្នាក់ដឹកនាំចំនួន១២% អន្តរាគមន៍ដោះស្រាយបញ្ហានានាចំនួន៤% និងចូលរួមវេទិកាសាធារណៈចំនួន១%។

## ២.៣ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សនីមួយៗ

ការសង្កេតឃើញថា គោលបំណងដែលក្រុមអ្នកតំណាងរាស្ត្រផ្តោតសំខាន់ជាងគេនោះ គឺការចុះសួរសុខទុក្ខប្រជាពលរដ្ឋចែកអំណោយ និងរួមទាំងសម្ពោធសមិទ្ធផលនានា ដែលគោលបំណងនេះ អ្នកតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិធ្វើសកម្មភាពចំនួន ៣៤៨លើក ហើយតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាធ្វើសកម្មភាពបានចំនួន៣៥៩លើក។ ចំពោះគោលបំណងចុះពង្រឹងបណ្តាញផ្ទៃក្នុងគណបក្ស តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិធ្វើសកម្មភាពបានចំនួន២០៩លើក ច្រើនជាងតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ដែលធ្វើសកម្មភាពចំនួន៥៧លើក។ ការធ្វើសកម្មភាពក្នុងគោលបំណងចុះអមដំណើរថ្នាក់ដឹកនាំ តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាធ្វើសកម្មភាពចំនួន ១៦៨លើក ហើយតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិចំនួន ៧៧លើក។ ការអន្តរាគមន៍ដោះស្រាយបញ្ហានានាវិញ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាចុះបាន២១លើក ហើយតំណាងរាស្ត្រគណបក្ស

សង្គ្រោះជាតិចុះបាន២៦លើក។ គោលបំណងចុងក្រោយ គឺការចូលរួមវេទិកាសាធារណៈតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិធ្វើសកម្មភាពចំនួន ៣លើក និងតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាចំនួន៥លើក។

*<u>តារាងទី១៖ ចំនួនលើកនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនៃគណបក្សនយោបាយនីមួយៗតាមគោលបំណង</u>*

ក្នុងឆ្នាំសង្កេតនេះ បានបង្ហាញឱ្យឃើញថា មានអ្នកតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា និងតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិចំនួន៩៦រូប ដែលស្មើនឹង៧៨%នៃចំនួនអ្នកតំណាងរាស្ត្រសរុប បានធ្វើសកម្មភាពក្នុងមូលដ្ឋានសរុប១២៧៤លើក។

| **គោលបំណងនៃការចុះមូលដ្ឋានទាំង១២៧៤ លើករបស់អ្នកតំណាងរាស្ត្រទាំង ៩៦រូប** | **គណបក្សនយោបាយ** | | **សរុប** |
|---|---|---|---|
| | **៥០រូប** | **៤៦រូប** | |
| ជួបសំណេះសំណាល សាកសួរសុខទុក្ខ និងចែកអំណោយ និងសម្ពោធសមិទ្ធផលនានា | ៣៥៩ | ៣៤៩ | **៧០៨**(**៥៥**%) |
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស | ៥៧ | ២០៩ | **២៦៦**(**២១**%) |
| ការចុះអមដំណើរជាក្រុមឬអមដំណើរថ្នាក់ដឹកនាំ | ១៦៨ | ៧៧ | **២៤៥**(**១៩**%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ៥ | ៣ | **៨**(**១**%) |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា | ២១ | ២៦ | **៤៧**(**៤**%) |
| **សរុបគោលបំណងតាមគណបក្ស** | **៦១០**(**៤៨**%) | **៦៦៤**(**៥២**%) | **១២៧៤**(**១០០**%) |

តារាងទី១នេះ បានបង្ហាញពីការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ភាគច្រើនផ្តោតទៅលើគោលបំណងជួបសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងសមិទ្ធផលនានាដែលចុះបាន៧០៨លើក (ស្មើនឹង៥៥%នៃការចុះមូលដ្ឋានសរុប)។ ការចុះមូលដ្ឋានក្នុងគោលបំណងទី២ អ្នកតំណាងរាស្ត្រផ្តោតទៅលើគោលបំណងចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សចុះបាន២៦៦លើក (ស្មើនឹង២១%នៃការចុះមូលដ្ឋានសរុប)។ គោលបំណងការអមដំណើរថ្នាក់ដឹកនាំគណបក្សរបស់ខ្លួនចុះបាន២៤៥លើក (ស្មើនឹង១៩%នៃចំនួនចុះមូលដ្ឋានសរុប)។ ចំណែកការចុះមូលដ្ឋាន ក្នុងគោលបំណងចូលរួមវេទិកា ឬសិក្ខាសាលាសាធារណៈចុះបាន០៨លើក(ស្មើនឹង១%នៃការចុះមូលដ្ឋានសរុប)។ គោលបំណងអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋចុះបានចំនួន៤៧លើក។

ការសង្កេតឃើញថា តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាចុះមូលដ្ឋាន ភាគច្រើនផ្តោតទៅលើការចុះសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋ និងគោលបំណងអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួន។ ចំណែកឯតំណាង

រាស្ត្រពីគណបក្សសង្គ្រោះជាតិវិញផ្តោតទៅលើការចុះសួរសុខទុក្ខប្រជាពលរដ្ឋ និងចុះពង្រឹងបណ្តាញផ្ទៃក្នុងគណបក្សរបស់ខ្លួន។

### ២.៤ មណ្ឌលរាជធានី ខេត្តដែលអ្នកតំណាងរាស្ត្របានចុះ

**ដំណើរការមិនប្រក្រតីនៃការិយាល័យតំណាងរាស្ត្រ**

ការិយាល័យតំណាងរាស្ត្រ ជាទីកន្លែងធ្វើការងាររបស់អ្នកតំណាងរាស្ត្រ នៅពេលដែលតំណាងរាស្ត្រចុះមូលដ្ឋាននោះ និងជាកន្លែងផ្សារភ្ជាប់ទំនាក់ទំនងរវាងតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ លើសពីនេះ ការិយាល័យតំណាងរាស្ត្រក៏ជាទីកន្លែងមួយ ដែលសម្រាប់បម្រើដល់ផលប្រយោជន៍ប្រជាពលរដ្ឋ ដោយមិនប្រកាន់ពីគណបក្សនយោបាយ និងជាកន្លែងមួយសម្រាប់ទទួលយកពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ដើម្បីធ្វើជូនទៅអ្នកតំណាងរាស្ត្រដែលជាអ្នកតំណាងរបស់ខ្លួនធ្វើការដោះស្រាយពិភាក្សាគ្នានៅក្នុងរដ្ឋសភា។

ក្នុងដើមនីតិកាលទី៥នេះ អ្នកសង្កេតការណ៍ខុមហ្វ្រែលប្រចាំក្នុងរាជធានី ខេត្តទាំងអស់ បានសង្កេតឃើញថា ដំណើរការនៃការិយាល័យតំណាងរាស្ត្រនៅតាមបណ្តាខេត្តមួយចំនួន ហាក់មានដំណើរការមិនប្រក្រតី ព្រោះមិនបានបំពេញតួនាទីការងាររបស់ខ្លួនឡើយ ដោយបានបិទទ្វារមិនដំណើរការ ឬដំណើរការមិនពេញលេញ។

ខេត្តចំនួន៣ដែលខុមហ្វ្រែលរកឃើញថា នៅមិនទាន់មានការិយាល័យតំណាងរាស្ត្រដូចជា ខេត្តកែប ខេត្តមណ្ឌលគីរី និងខេត្តឧត្តរមានជ័យ។

ខុមហ្វ្រែលបានពិនិត្យឃើញដែរថា ក្នុងចំណោមរាជធានី ខេត្ត ដែលមានការិយាល័យតំណាងរាស្ត្រ មានការិយាល័យចំនួន១៧បានបើកដំណើរការ និងបំពេញតួនាទីការងាររបស់ខ្លួន រួមមានខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តកំពត ខេត្តកណ្តាល ខេត្តប៉ៃលិន ខេត្តកោះកុង ខេត្តក្រចេះ ខេត្តព្រះវិហារ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង ខេត្តស្វាយរៀង ខេត្តតាកែវ ខេត្តកំពង់ឆ្នាំង និងរាជធានីភ្នំពេញ។ ទន្ទឹមនឹងនេះក៏មានសេចក្តីរាយការណ៍ថា ការិយាល័យមួយចំនួនដែលបើកដំណើរការនោះនៅមិនទាន់អនុវត្តតួនាទីរបស់ខ្លួនពេញលេញនៅឡើយ។

ដោយឡែកការិយាល័យតំណាងរាស្ត្រក្នុងខេត្តចំនួនបី មិនសូវបានបើកដំណើរការ និងបំពេញតួនាទីការងាររបស់ខ្លួនទេ ក្នុងនោះរួមមាន ការិយាល័យក្នុងខេត្តកំពង់ស្ពឺ ខេត្តព្រៃវែង និងខេត្តពោធិ៍សាត់។

## III. ការទំនាក់ទំនង និងអន្តរាគមន៍របស់អ្នកតំណាងរាស្ត្រ និងរដ្ឋសភា

### ៣.១ វេទិកាសួរអ្នកតំណាងរាស្ត្រ

នេះជាឆ្នាំទី១ហើយ ដែលខុមហ្វ្រែលបានបង្កើតកម្មវិធីវេទិកាសួរអ្នកតំណាងរាស្ត្រដើម្បីផ្សារភ្ជាប់ពីតំណាងរាស្ត្រ និងម្ចាស់ឆ្នោត រួមទាំងបានផ្តល់ឱកាសសម្រាប់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតមានឱកាស ក្នុងផ្តល់ព័ត៌មានពីបញ្ហានានាមួយចំនួននៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីជូនទៅអ្នកតំណាងរាស្ត្ររបស់ខ្លួនធ្វើការដោះស្រាយ។

សម្រាប់ដើមនីតិកាលទី៥នៃរដ្ឋសភានេះ កម្មវិធីវេទិកាសួរអ្នកតំណាង (Ask Your MPs) មានតំណាងរាស្ត្រចំនួន២គណបក្ស ដែលមានអាសនៈនៅក្នុងរដ្ឋសភាជាតិ បានចូលរួមក្នុងការផ្តល់ចម្លើយតបមកកម្មវិធីនេះ។

ក្នុងកម្មវិធីវេទិកាសួរអ្នកតំណាង មានអ្នកតំណាងរាស្ត្រចំនួន៣០រូប មកពីគណបក្សគណបក្សប្រជាជនកម្ពុជាចំនួន២រូប (ស្មើនឹង៣%នៃអាសនៈសរុបរបស់ខ្លួនក្នុងរដ្ឋសភា) និងគណបក្សសង្គ្រោះជាតិ២៨រូប (ស្មើនឹង៥១%នៃអាសនៈសរុបរបស់ខ្លួនក្នុងរដ្ឋសភា)។ ក្នុងចំណោមតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាចំនួន២រូប មានតំណាងរាស្ត្រចំនួន១រូប បានដកខ្លួនចេញពីការចូលរួមវេទិកាសួរអ្នកតំណាង ដោយហេតុផលថាមិនមានថវិកាក្នុងការផ្ញើចម្លើយតបមកកម្មវិធីវិញ។

ក្នុងចំណោមតំណាងរាស្ត្រដែលបានចូលរួមក្នុងកម្មវិធីវេទិកាសួរអ្នកតំណាង មានតែតំណាងរាស្ត្រចំនួន៦រូប របស់គណបក្សសង្គ្រោះជាតិប៉ុណ្ណោះ ដែលបានព្យាយាមក្នុងការឆ្លើយតបទៅនឹងសំណួររបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាមមូលដ្ឋានរបស់ខ្លួន។ អ្នកតំណាងរាស្ត្រទាំង៦រូប នោះមាន អ្នកតំណាងរាស្ត្រ កែវ ភីរម្យ មណ្ឌលក្រចេះ អ្នកតំណាងរាស្ត្រ ឡុង ប៊ុត្តា មណ្ឌលបាត់ដំបង អ្នកតំណាងរាស្ត្រ អេង ឆៃអ៊ាង មណ្ឌលកណ្តាល អ្នកតំណាងរាស្ត្រ យឹម សុវណ្ណ មណ្ឌលភ្នំពេញ និងអ្នកតំណាងរាស្ត្រ អ៊ុំ សំអាន មណ្ឌលសៀមរាប។ ក្នុងចំណោមតំណាងរាស្ត្រទាំង៦រូបដែលបានឆ្លើយតបមកប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនោះ មានតំណាងរាស្ត្រចំនួន២រូប ដែលបានសកម្មឆ្លើយតបនឹងសំណួរច្រើនជាងគេ ក្នុងនោះមានអ្នកតំណាងរាស្ត្រ កែវ ភីរម្យ និងអ្នកតំណាងរាស្ត្រ ឡុង ប៊ុត្តា។

ក្នុងអំឡុងពេលចាប់ពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ២០១៤ ខុមហ្វ្រែល (ដើរតួជាអន្តរការី) បានទទួលសំណួរពីប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតសួរទៅកាន់អ្នកតំណាងរាស្ត្រក្នុងកម្មវិធីវេទិកាសួរអ្នកតំណាង តាមរយៈជាសារជាអក្សរ អ៊ីម៉ែល និងបណ្តាញសង្គមហ្វេសប៊ុកបានចំនួន៥០៤សំណួរ ដែលមានការឆ្លើយតបមកវិញ តាមរយៈអ្នកតំណាងរាស្ត្របានចំនួន១៨១ចម្លើយ។

គោលបំណងនៃសំណួររបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត នៅក្នុងវេទិកាសួរអ្នកតំណាង ភាគច្រើនផ្តោតទៅលើការសុំឱ្យដោះស្រាយបញ្ហាពាក់ព័ន្ធទំនាស់ដីធ្លី ធ្វើផ្លូវ ស្តារប្រឡាយទឹក សាងសង់អគារសាលា និងសុំឱ្យអ្នកតំណាងរាស្ត្រចុះតាមមូលដ្ឋានឱ្យបានច្រើនជាដើម។

### ៣.២ ការចេញលិខិតអន្តរាគមន៍របស់អ្នកតំណាងរាស្ត្រ

ក្នុងឆ្នាំសង្កេតនេះ(កញ្ញា២០១៣ ដល់តុលា២០១៤) ខុមហ្វ្រែលទទួលទិន្នន័យពីអ្នកតំណាងរាស្ត្រដែលបានចេញលិខិតទៅរាជរដ្ឋាភិបាល មានតំណាងរាស្ត្រតែមួយគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា បានធ្វើលិខិតទៅរាជរដ្ឋាភិបាល ដើម្បីក្នុងគោលបំណងស្នើវិធានការ/អំពាវនាវឲ្យស្ថាប័នរាជរដ្ឋាភិបាល ដើម្បីចាត់វិធានការអន្តរាគមន៍ទៅលើបញ្ហានានាដែលអ្នកតំណាងរាស្ត្របានប្រមូលព័ត៌មាន និងបានទទួលពីប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត។

ខុមហ្វ្រែលបានសង្កេតឃើញថា មានអ្នកតំណាងរាស្ត្រចំនួន១១រូបមកពីគណបក្សសង្គ្រោះជាតិ បានចេញលិខិតសរុបចំនួន១៨ច្បាប់។ ចំពោះតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមានអាសនៈនៅក្នុងរដ្ឋសភា ដែលជាគណបក្សកាន់អំណាចក្នុងរយៈពេលមួយឆ្នាំ(កញ្ញា២០១៣ដល់តុលា២០១៤)នេះ ខាងខុមហ្វ្រែលមិនបានទទួលព័ត៌មានណាមួយពីការដាក់លិខិតទៅរាជរដ្ឋាភិបាលនោះទេ។

ការចេញលិខិតរបស់អ្នកតំណាងរាស្ត្រ នៅក្នុងឆ្នាំទី១នេះ ខុមហ្វ្រែលទទួលបានលិខិតប្រភេទការស្នើចាត់វិធានការ/អំពាវនាវដល់រាជរដ្ឋាភិបាលជួយអន្តរាគមន៍ លិខិតបញ្ចេញមតិ និងលិខិតកោះហៅរាជរដ្ឋាភិបាលមកបំភ្លឺនៅក្នុងរដ្ឋសភា ចំណែកលិខិតក្នុងគោលបំណងអន្តរាគមន៍ដោយផ្ទាល់របស់តំណាងរាស្ត្រ ខាងខុមហ្វ្រែលមិនបានទទួលព័ត៌មានណាមួយពីគណបក្សនយោបាយទាំងពីរគណបក្សនោះទេ។

ខុមហ្វ្រែល សង្កេតឃើញថា លិខិតរបស់តំណាងរាស្ត្រទាំង១៨ច្បាប់ ក្នុងនោះមានលិខិតក្នុងគោលបំណងអំពាវនាវ/ស្នើចាត់វិធានការចំនួន១៣ច្បាប់ លិខិតបែបបញ្ចេញមតិចំនួន១ច្បាប់ និងលិខិតកោះហៅរដ្ឋមន្ត្រីមកបំភ្លឺក្នុងរដ្ឋសភា ខុមហ្វ្រែលទទួលទិន្នន័យបានតែ៤ច្បាប់ប៉ុណ្ណោះពីតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ។ ចំពោះលិខិតទាំង១៨ច្បាប់របស់អ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ខុមហ្វ្រែលបានទទួលព័ត៌មានមានលិខិតចំនួន៥ច្បាប់មានការឆ្លើយតបពីរាជរដ្ឋាភិបាល។

*តារាង១៖ ឈ្មោះអ្នកតំណាងរាស្ត្រទាំង១១ រូបដែលបានចេញលិខិត និងគោលបំណងនៃលិខិត*

| លរ | គោត្តនាមនិងនាម | គណបក្ស | ចំនួន | គោលបំណងនៃលិខិត | | | | | ការឆ្លើយតប |
|---|---|---|---|---|---|---|---|---|---|
| | | | | អន្តរា | អំពាវ | បញ្ | ដាក់ | បំភ្លឺនៃ | |
| ១ | ឯកឧត្តម ម៉ែន សុថាវរិន្ទ្រ | | ៤ | 0 | ៤ | 0 | 0 | 0 | 0 |
| ២ | ឯកឧត្តម សុន ឆ័យ | | ១ | 0 | ១ | 0 | 0 | 0 | 0 |
| ៣ | កែ សុវណ្ណរតន៍ | | ១ | 0 | 0 | ១ | 0 | 0 | 0 |
| ៤ | ឯកឧត្តម គី វណ្ណដារ៉ា | | ៣ | 0 | ៣ | 0 | 0 | 0 | 0 |
| ៥ | ឯកឧត្តម គឹម សុខា | | ១ | 0 | ១ | 0 | 0 | 0 | 0 |
| ៦ | ឯកឧត្តម អេង ឆៃអ៊ាង | | ១ | 0 | ១ | 0 | 0 | 0 | 0 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៧ | ឯកឧត្តម យ៉ែម បុញ្ញឫទ្ធិ | | ៦ | ០ | ២ | ០ | ០ | ៤ | ៥ |
| ៨ | លោកជំទាវ តែ ច័ន្ទមុនី | | ១ | ០ | ១ | ០ | ០ | ០ | ០ |
| ៩ | ឯកឧត្តម ហូរ វ៉ាន់ | | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ១០ | ឯកឧត្តម ងឹម ញៀង | | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ១១ | ឯកឧត្តម ង៉ោ គឹមជាង | | ០ | ០ | ០ | ០ | ០ | ០ | ០ |
| **សរុប** | | | **១៨** | **០** | **១៣** | **១** | **០** | **៤** | **៥** |

ជាក់ស្តែងនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ អ្នកតំណាងរាស្ត្រ ម៉ែន សុថាវិរិន្ទ្រ មណ្ឌលកំពង់ធំមកពីគណបក្សសង្គ្រោះជាតិ បានដាក់លិខិតមួយច្បាប់ជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្នើសុំចាត់វិធានការចំពោះក្រុមហ៊ុន វីស៊ីមេនផាវវ័រ លើករណីបាត់ខ្លួនកម្មការនីឈ្មោះកែម ចន្ទី ដែលមានលេខកូដសម្គាល់ខ្លួន ២៧៦៧ ដោយយោងតាមពាក្យបណ្តឹងចុះនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤ របស់ប្រជាពលរដ្ឋឈ្មោះ ក្លាន់ កែម និងឈ្មោះ រុន ឡាំ នៅភូមិពាមអាទិត្យ ឃុំសាគ្រាម ស្រុកបាសាទបល្ល័ង្គ ខេត្តកំពង់ធំ។

### ៣.៣ បញ្ហាលំបាកក្នុងការទំនាក់ទំនងទៅរដ្ឋសភា

ប្រហាក់ប្រហែលរដ្ឋសភានីតិកាលទី៤ រដ្ឋសភានីតិកាលទី៥នេះនៅតែមានការលំបាកក្នុងការទំនាក់ទំនងសាកសួរព័ត៌មាន ជាពិសេសកិច្ចសហការក្នុងការទំនាក់ទំនងទៅអ្នកតំណាងរាស្ត្រ។ ជាក់ស្តែងនៅដើមនីតិកាលនេះ ខុមហ្វ្រែលបានទំនាក់ទំនងទៅរដ្ឋសភា ដើម្បីស្នើកិច្ចសហការផ្តល់ព័ត៌មានទៅអ្នកតំណាងរាស្ត្រ ក្នុងគម្រោងចងក្រងសៀវភៅប្រវត្តិរូបសង្ខេបអ្នកតំណាងរាស្ត្រ នីតិកាលទី៤ និងកម្មវិធីវេទិកាសួរអ្នកតំណាង ប៉ុន្តែមិនទទួលបានការឆ្លើយតបជាវិជ្ជមានពីរដ្ឋសភានោះទេ។

គួរបញ្ជាក់ថា ការចងក្រងសៀវភៅប្រវត្តិរូបសង្ខេបអ្នកតំណាងរាស្ត្រ គឺដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋម្ចាស់ឆ្នោតក្នុងការយល់ដឹងព័ត៌មានចាំបាច់នានាអំពីដំណើរការ រចនាសម្ព័ន្ធ តួនាទី សិទ្ធិអំណាចរបស់រដ្ឋសភា និងអ្នកតំណាងរាស្ត្រ ព្រមទាំងប្រវត្តិសង្ខេប និងមធ្យោបាយក្នុងការទំនាក់ទំនងអ្នកតំណាងរាស្ត្រ។ ជាមួយគ្នានេះវេទិកាសួរអ្នកតំណាងរៀបចំឡើង ក្នុងគោលបំណងឱ្យអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតទំនាក់ទំនងគ្នាដើម្បីទទួលព័ត៌មាន និងដោះស្រាយបញ្ហានានារបស់ម្ចាស់ឆ្នោត។

គម្រោងទាំងពីរ គណៈកម្មាធិការខុមហ្វ្រែល បានដាក់លិខិតទៅអ្នកតំណាងរាស្ត្រតាមរយៈរដ្ឋសភាដោយស្នើសុំឱ្យរដ្ឋសភាជួយសម្របសម្រួលបញ្ជូនលិខិតទាំងនោះទៅដល់ដៃអ្នកតំណាងរាស្ត្រ។ ការដាក់លិខិតនេះបានធ្វើឡើងកាលពីអំឡុងខែកុម្ភៈ និងខែកញ្ញា ឆ្នាំ២០១៤ ប៉ុន្តែត្រូវបានរដ្ឋសភាបដិសេធ និងឱ្យខុមហ្វ្រែលយកលិខិត

ទាំងនោះមកវិញ និងព្រមទាំងប្រាប់ឱ្យខុមហ្វ្រែលរកមធ្យោបាយដោយខ្លួនឯងក្នុងការបញ្ជូនលិខិតទាំងនោះទៅអ្នកតំណាងរាស្ត្រ។

ការលំបាកផ្សេងទៀត គឺការទំនាក់ទំនងស្នើសុំសេចក្តីព្រាង/ស្នើច្បាប់ក្នុងដៃរដ្ឋសភា ដើម្បីចូលរួមពិនិត្យ និងផ្តល់យោបល់ ការទំនាក់ទំនងស្នើសុំព័ត៌មានផ្សេងទៀត និងរបាយការណ៍នានារបស់រដ្ឋសភាជាដើម។

### ៣.៤ កំណត់ហេតុប្រជុំពេញអង្គរបស់រដ្ឋសភា និងគណៈកម្មការជំនាញ

ការរៀបចំធ្វើកំណត់ហេតុកិច្ចប្រជុំពេញអង្គរដ្ឋសភា និងគណៈកម្មការនានារបស់រដ្ឋសភា គឺជាបន្ទុករបស់អគ្គលេខាធិការដ្ឋានរដ្ឋសភា។ ជាមួយគ្នានេះ អគ្គលេខាធិការដ្ឋាន ទទួលរ៉ាប់រងនូវរាល់គ្រប់កិច្ចការរដ្ឋបាល និងសេវានានាជូនរដ្ឋសភា និងគណៈកម្មការទាំងអស់។

គួរបញ្ជាក់ថា រដ្ឋសភាកន្លងនេះមក បានចេញរបាយការណ៍ពីកំណត់ហេតុសង្ខេបពីកិច្ចប្រជុំពេញអង្គរដ្ឋសភា និងគណៈកម្មការជំនាញរដ្ឋសភាតែប៉ុណ្ណោះ។ ជុំវិញរបាយការណ៍លម្អិត ខុមហ្វ្រែលបានដាក់លិខិតស្នើសុំទៅអគ្គលេខាធិការដ្ឋានរដ្ឋសភា ក្នុងគោលបំណងស្នើសុំឯកសារទាំងនោះដើម្បីទុកជាព័ត៌មាន និងធ្វើជាឯកសារយោងសម្រាប់របាយការណ៍ឃ្លាំមើលសភា។

ជាស្តែងនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា(ខុមហ្វ្រែល) បានដាក់លិខិតចំនួន២ច្បាប់ជូនប្រធានរដ្ឋសភា សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ក្នុងកម្មវត្ថុស្នើសុំការអនុញ្ញាតចូលសង្កេតរាល់ការកិច្ចប្រជុំគណៈកម្មការជំនាញនានា ស្តីពីសេចក្តីព្រាងច្បាប់ និងស្នើច្បាប់ និងការកោះហៅមន្ត្រីរាជរដ្ឋាភិបាលបំភ្លឺអំពីការអនុវត្តច្បាប់ និងស្នើសុំកំណត់ហេតុលំអិតនៃកិច្ចប្រជុំពេញអង្គសាមញ្ញលើកទី៩ នីតិកាលទី៤នៃរដ្ឋសភា សម័យប្រជុំថ្ងៃទី០៦-០៧ ខែធ្នូ ឆ្នាំ២០១២ តែមកដល់ពេលនេះរដ្ឋសភានៅមិនទាន់ឆ្លើយតបណាមួយឡើយទេ។

### ៣.៥ មន្ត្រីបម្រើការនៅក្នុងរដ្ឋសភា (មន្ត្រីខ្មោច)

ជារឿយៗ ស្ថាប័នសាធារណៈរបស់រដ្ឋតែងតែទទួលរងការចោទប្រកាន់ថា មន្ត្រីមួយចំនួនបម្រើការនៅស្ថាប័នទាំងនោះ មិនបានបំពេញមុខងាររបស់ខ្លួនទៀងទាត់ ធ្វើការមិនពេញម៉ោង ហើយមួយចំនួនមិនបានទៅបម្រើការងារប្រចាំថ្ងៃទេ ប៉ុន្តែពួកបានទទួលប្រាក់បៀវត្សប្រចាំខែជាធម្មតា។ ករណីនេះ បានធ្វើឱ្យសេវាសាធារណៈរបស់ស្ថាប័នទាំងនេះមិនសូវមានប្រសិទ្ធភាព និងយឺតយ៉ាវ ហើយថវិកាជាតិត្រូវបានចំណាយទៅស្ថាប័នទាំងនោះដោយមិនមានប្រសិទ្ធភាពដែរ។

មិនខុសគ្នាទៅនឹងស្ថាប័នសាធារណៈរបស់អង្គនីតិប្រតិបត្តិ អង្គនីតិបញ្ញត្តិក៏ទទួលរងនូវការិះគន់អំពីបញ្ហាមន្ត្រីរបស់ស្ថាប័ននេះ មួយចំនួនមិនបានបំពេញការងាររបស់ខ្លួនជារាងរាល់ថ្ងៃឡើយ។ ជាក់ស្តែងអ្នកតំណាងរាស្ត្រ សុន ឆ័យ មណ្ឌលភ្នំពេញ នៃគណបក្សសង្គ្រោះជាតិបានអះអាងថា បច្ចុប្បន្នបុគ្គលិកបម្រើការងារនៅក្នុងរដ្ឋសភា

មានជិត ២៣ពាន់នាក់ តែមកធ្វើការជាប្រចាំថ្ងៃតែ៣ ទៅ៤រយនាក់តែប៉ុណ្ណោះ។ ក្នុងអាណត្តិនេះ រូបលោកនឹងធ្វើសកម្មភាពប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ គ្រួសារនិយមនៅក្នុងស្ថាប័នកំពូលរបស់រដ្ឋមួយនេះ និងត្រៀមវែកមុខមន្ត្រីខ្មោចទាំងនោះ។ លោកបានគូសបញ្ជាក់ថា ការកែទម្រង់ទាំងឡាយរបស់រដ្ឋត្រូវចាប់ផ្តើមពីស្ថាប័ននីតិបញ្ញត្តិនេះមុនគេ ដែលត្រូវបង្ហាញគំរូដល់ស្ថាប័នជាតិដទៃទៀត។ ទាក់ទងករណីនេះ កាលពីថ្ងៃទី២១ ខែតុលា កន្លងទៅ ក្នុងនាមអនុប្រធានគណៈកម្មការហិរញ្ញវត្ថុនៃរដ្ឋសភា អ្នកតំណាងរាស្ត្រ សុន ឆ័យ បានដាក់លិខិតទៅអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាននៃរដ្ឋសភា ឲ្យបើកការស៊ើបអង្កេតលើករណីគ្រួសារនិយមនៅក្នុងស្ថាប័ននេះ។ លិខិតរបស់លោក សុន ឆ័យ បានចោទប្រកាន់ចំៗថា លោក មិត្ត ការ៉េន អគ្គលេខាធិការរងនៃរដ្ឋសភា បានប្រើប្រាស់អំណាចរបស់ខ្លួន តែងតាំងគ្រួសារខ្លួនជាច្រើននាក់ឲ្យបម្រើការងារនៅក្នុងរដ្ឋសភា ដែលធ្វើឲ្យខាតបង់ថវិកាជាតិ និងមានអំពើពុករលួយជាប្រព័ន្ធនៅក្នុងស្ថាប័ននេះ។ ហើយគ្រួសាររបស់ លោក មិត្ត ការ៉េន នោះ ភាគច្រើនពួកគេបានកាន់តំណែងជាអ្នកបើកប្រាក់បៀវត្សតំណាងរាស្ត្រក្នុងរដ្ឋសភា អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋសភា និងកាន់តំណែងជានាយកដ្ឋានសវនកម្មផ្ទៃក្នុងរដ្ឋសភា។

ជុំវិញករណីនេះ លោក កឹម សុខា ក្នុងនាមអនុប្រធានទី១នៃរដ្ឋសភា បានឲ្យដឹងថា លោកកំពុងតាមដាន និងស្រាវជ្រាវបញ្ហានេះ។ ប៉ុន្តែប្រធានរដ្ឋសភា និងអគ្គលេខាធិការនៃរដ្ឋសភាមិនបានឆ្លើយតបទៅនឹងសំណើរបស់អ្នកតំណាងរាស្ត្រ សុន ឆ័យឡើយ។

## IV. **អំពីអ្នកតំណាងរាស្ត្រ**

### ៤.១ ព័ត៌មានអំពីស្ថានភាពអ្នកតំណាងរាស្ត្រ

សម្រាប់រដ្ឋសភានីតិកាលទី៥នេះ ខុមហ្វ្រែលបានបន្តចងក្រងជាសៀវភៅប្រវត្តិរូបសង្ខេបរបស់តំណាងរាស្ត្រ ដើម្បីផ្តល់ឱ្យសហគមន៍ អង្គការ ស្ថាប័ន ជាពិសេសប្រជាពលរដ្ឋនូវឧបករណ៍ និងព័ត៌មានចាំបាច់នានាក្នុងការធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងអំពីដំណើរការ រចនាសម្ព័ន្ធ តួនាទី សិទ្ធិ និងអំណាចរបស់រដ្ឋសភា និងតំណាងរាស្ត្រ។ ព័ត៌មានចាំបាច់មួយចំនួនរបស់អ្នកតំណាងរាស្ត្រ ដូចជាប្រវត្តិសង្ខេប អាសយដ្ឋាន លេខទូរស័ព្ទ កម្រិតវប្បធម៌ ជំនាញឯកទេស វិស័យដែលអ្នកតំណាងរាស្ត្រមានចំណាប់អារម្មណ៍ និងបទពិសោធន៍ការងារជាដើម ត្រូវរៀបរាប់ក្នុងសៀវភៅនេះ ដើម្បីជួយបង្កើននូវការយល់ដឹងកាន់តែធំធេងឡើងសម្រាប់ម្ចាស់ឆ្នោត និងជាស្ពានទំនាក់ទំនងរវាងអ្នកតំណាងរាស្ត្រជាមួយប្រជាពលរដ្ឋ សហគមន៍ ស្ថាប័ន និងអង្គការនានា។

រដ្ឋសភានីតិកាលទី៥នេះ មានតំណាងរាស្ត្រចំនួន១២៣រូប ក្នុងនោះមានតំណាងរាស្ត្រស្រីចំនួន២៥រូបមកពីគណបក្សចំនួនពីរ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ។

### ៤.២.១ ក្រុមអាយុ និងកម្រិតវប្បធម៌របស់អ្នកតំណាងរាស្ត្រ

មានអ្នកតំណាងរាស្ត្រជាយុវជន អាយុចន្លោះពី២៥ឆ្នាំ ដល់៣៥ឆ្នាំ មានចំនួន៣រូប។

***១-ក្រាហ្វិកកំណត់ពីអាយុអ្នកតំណាងរាស្ត្រ***




តាមតារាងក្រាហ្វិកបានបង្ហាញឲ្យឃើញថា ទាំងតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា និងតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ចាប់ពីអាយុ២៥ឆ្នាំ ដល់៣៩ឆ្នាំមាន ចំនួន ១១រូប អាយុចាប់ពី៤០ ដល់៤៩ឆ្នាំ មាន ចំនួន១៩រូប អាយុចាប់ពី៥០ ដល់៥៩ឆ្នាំ មានចំនួន៣១រូប អាយុចាប់៦០ ដល់៦៩ឆ្នាំ មានចំនួន៥០រូប និងអាយុ៧០ឆ្នាំឡើងទៅ មានចំនួនតំណាងរាស្ត្រ១២រូប។

អំពីកម្រិតវប្បធម៌របស់អ្នកតំណាងរាស្ត្រនៃរដ្ឋសភានីតិកាលទី៥នេះ បើតាមព័ត៌មានដែលខុមហ្វ្រែលប្រមូល បានឃើញថា តំណាងរាស្ត្រភាគច្រើនមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាប័ត្រ និងបរិញ្ញាប័ត្រជាន់ខ្ពស់ ចំពោះថ្នាក់បណ្ឌិត និងមធ្យមសិក្សាកម្រិតពីរមានចំនួនមធ្យម។ ចំណែកឯកកម្រិតវប្បធម៌ថ្នាក់បណ្ឌិតកិត្តិយស និងត្រឹមថ្នាក់បឋមសិក្សាមានចំនួនតិចតួច។

តំណាងរាស្ត្រដែលមានកម្រិតវប្បធម៌ថ្នាក់បណ្ឌិតចំនួន១១រូប ថ្នាក់បណ្ឌិតកិត្តិយសចំនួន៥រូប ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ចំនួន២៩រូប ថ្នាក់បរិញ្ញាប័ត្រចំនួន៤០រូប កម្រិតមធ្យមសិក្សាកម្រិតពីរចំនួន១១រូប និងកម្រិតបឋមសិក្សាចំនួន១រូប។ ជាការពិត សញ្ញាបត្រដែលបញ្ជាក់កម្រិតវប្បធម៌នេះ ត្រូវបានផ្ទៀងផ្ទាត់ថា តើកម្រិតនៃការទទួលស្គាល់ផ្លូវការមានយ៉ាងណានោះទេ?

### ៤.២.២ អាសយដ្ឋានអ្នកតំណាងរាស្ត្រ

អ្នកតំណាងរាស្ត្រចំនួន៦៣រូប មានអាសយដ្ឋាននៅក្នុងមណ្ឌលរបស់ខ្លួន និង៨រូបទៀតមិនមានអាសយដ្ឋាននៅក្នុងមណ្ឌលរបស់ខ្លួននោះទេ។ ចំណែកអ្នកតំណាងរាស្ត្រចំនួន៥២រូបទៀត ខុមហ្វ្រែលមិនបានទទួលព័ត៌មានពីអាសយដ្ឋាននៅក្នុងមណ្ឌលនោះទេ។

## V. ការផ្លាស់ប្តូរថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពតំណាងរាស្ត្រ

### ៥.១ ករណីផ្លាស់ប្តូរថ្នាក់ដឹកនាំរដ្ឋសភា

យោងតាមប្រការ២ ថ្មី (ពីរ) ចំណុច ក.២ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាបានបញ្ញត្តិថា "បោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវ ប្រធាន អនុប្រធានទាំងពីររបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល"។ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាមិនបានបញ្ញត្តិអំពីនីតិវិធីក្នុងករណីផ្លាស់ប្តូរថ្នាក់ដឹកនាំរដ្ឋសភា។

កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ រដ្ឋសភាបានបើកសម័យប្រជុំវិសាមញ្ញរដ្ឋសភា ដើម្បីធ្វើការបោះឆ្នោតជ្រើសតាំងលោក កឹម សុខា ជាអនុប្រធានទី១ នៃរដ្ឋសភាជំនួសលោក ងួន ញិល។ គួររំលឹកថា នៅមុនតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិចូលរដ្ឋសភា ថ្នាក់ដឹកនាំរដ្ឋសភាដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ដែលមានលោក ហេង សំរិន ជាប្រធាន លោក ងួង ញិល ជាអនុប្រធានទី១ និងលោកស្រី ឃួន សុដារី ជាអនុប្រធានទី២។

ករណីផ្លាស់ប្តូរថ្នាក់ដឹកនាំរដ្ឋសភា ត្រូវបានមើលឃើញថា រដ្ឋសភាមិនមាននីតិវិធីជាអំណះអំណាងឡើយដោយការដោះដូរ។

នីតិវិធីគួរធ្វើឱ្យតំណែងអនុប្រធានទី១ និងអនុប្រធានទី២ នៃរដ្ឋសភានៅទំនេរ ហើយបន្ទាប់មកត្រូវបោះឆ្នោតជ្រើសរើសបំពេញកន្លែងដែលទំនេរនោះ។ ក្នុងករណីនេះលោក ងួន ញិល អនុប្រធានទី១ និងលោកស្រី ឃួន សុដារី អនុប្រធានទី២ នៃរដ្ឋសភា ត្រូវលាឈប់ ឬត្រូវដកពីតំណែង បន្ទាប់មកត្រូវធ្វើការបោះឆ្នោតជ្រើសរើសជំនួសតំណែងនោះ។ លោក កឹម សុខា ត្រូវបានបោះឆ្នោតជ្រើសរើសដោយសមាជិករដ្ឋសភាដើម្បីជំនួសតំណែងលោក ងួន ញិល ដែលជាអនុប្រធានទី១នៃរដ្ឋសភា ហើយលោក ងួន ញិល ត្រូវបានបោះឆ្នោតជំនួសតំណែងលោកស្រី ឃួន សុដារី ដែលជាអនុប្រធានទី២នៃរដ្ឋសភា។ លោកស្រី ឃួន សុដារី ត្រូវបានក្លាយទៅជាអ្នកតំណាងរាស្ត្រធម្មតា។ គួរបញ្ជាក់នៅអំឡុងកិច្ចប្រជុំវិសាមញ្ញនោះ រដ្ឋសភាមិនបានលើកអំណះអំណាងអំពីនីតិវិធីច្បាប់ជុំវិញការផ្លាស់ប្តូរនេះទេ។

ការផ្លាស់ប្តូរតំណែងថ្នាក់ដឹកនាំរដ្ឋសភាបានធ្វើឡើងដោយមិនមានតម្លាភាព អនុវត្តដោយមិនមាននីតិវិធីច្បាស់លាស់។

## ៥.២ ការដោះដូរអ្នកតំណាងរាស្ត្រ

បើយោងតាមមាត្រា ១២០ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានបញ្ញត្តិថា កាលបើសមាជិករដ្ឋសភារូបណាមួយត្រូវបាត់បង់សមាជិកភាពមានរយៈពេលប្រាំមួយ(៦)ខែ យ៉ាងតិច មុនចប់នីតិកាល សាមីគណបក្សនយោបាយនោះ អាចស្នើជ្រើសតាំងសមាជិកថ្មីជំនួស ដោយជ្រើសរើសក្នុងចំណោមបេក្ខជនដែលមានឈ្មោះ តាមលំដាប់លេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃមណ្ឌលបោះឆ្នោតរបស់សាមីខ្លួននោះមកជំនួស ដោយមិនបាច់បោះឆ្នោតឡើងវិញ។ សមាជិករដ្ឋសភាត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ទៅតាមករណីណាមួយដូចខាងក្រោម៖

- សាមីខ្លួនទទួលមរណភាព។
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។
- សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិករដ្ឋសភា។
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។
- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន។

ច្បាប់ក៏ដូចជានីតិវិធីបោះឆ្នោត មិនបានចង្អុលបង្ហាញ ឬបញ្ញត្តិអំពីនីតិវិធីនៃការផ្លាស់ប្តូរបេក្ខជនជាប់ឆ្នោតនៅដំណាក់កាលដែល គ.ជ.ប ប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រនោះទេ ដូច្នេះការអនុវត្តរបស់ គ.ជ.ប ដែលបានប្រកាសដោះដូរបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រជាការអនុវត្តន៍ដោយគ្មានតម្លាភាពដោយ "សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិករដ្ឋសភា" ដែលសាធារណជន ម្ចាស់ឆ្នោតមណ្ឌលនីមួយៗមិនទទួលបានព័ត៌មាន។ មេដឹកនាំគណបក្សកាន់អំណាចតែងតែដក ដាក់ និងធ្វើការផ្លាស់ប្តូរស្រេចតែចិត្ត។

### ៥.២.១ ករណីមណ្ឌលកំពង់ស្ពឺ

ការប្រកាសទទួលស្គាល់ជាផ្លូវការ ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះរបស់ គ.ជ.ប បានបង្ហាញថា លោក សាយ ឈុំ ឈរឈ្មោះក្នុងលេខរៀងទី១ លោក ឆាយ ថន លេខរៀងទី២ លោក កង ហ៊ាង លេខរៀងទី៣ លោក ហ៊ុន ម៉ានី លេខរៀងទី៤ លោក ហែម ខន លេខរៀងទី៥ និងលោក សត្យា វុធ ឈរឈ្មោះក្នុងលេខរៀងទី៦ នៃបញ្ជីបេក្ខជនពេញសិទ្ធិ។ លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ បានបង្ហាញថា គណបក្សប្រជាជនកម្ពុជាទទួលបាន ៣អាសនៈ ហើយគណបក្សសង្គ្រោះជាតិទទួលបាន ៣អាសនៈនៃអាសនៈសរុបចំនួន ៦។

ក្នុងចំណោម ៣អាសនៈដែលគណបក្សប្រជាជនកម្ពុជាទទួលបាន គ.ជ.ប បានបង្ហាញបេក្ខជនជាប់ឆ្នោត ៣រូបគឺ លោក កង ហ៊ាង លោក ហ៊ុន ម៉ានី និងលោកហែម ខន។ បើយោងតាមបញ្ជីបេក្ខជនពេញសិទ្ធិ បេក្ខជនជាប់ឆ្នោតគឺ លោក សាយ ឈុំ លោក ឆាយ ថន និងលោក កង ហ៊ាង។

### ៥.២.២ ករណីមណ្ឌលបាត់ដំបង

ដូចករណីខាងលើ ការឃ្លាំមើលសូមលើករណីមួយផ្សេងទៀតទាក់ទងការផ្លាស់ប្តូរសមាសភាពបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រនៅមណ្ឌលបាត់ដំបង។ យោងតាមលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ បានបង្ហាញថា គណបក្សប្រជាជនកម្ពុជាទទួលបាន ៥អាសនៈ ហើយគណបក្សសង្គ្រោះជាតិទទួលបាន ៣អាសនៈនៃអាសនៈសរុប៨។ បេក្ខជនពេញសិទ្ធិនៃគណបក្សប្រជាជនកម្ពុជាលំដាប់លេខរៀងទី១គឺ លោក ស ខេង ទី២ លោក ងិន យន ទី៣ លោក សក់ សេដ្ឋា ទី៤ លោក នឹម ចូត និងទី៥ លោកស្រី លី គឹមលៀង ប៉ុន្តែនៅពេល គ.ជ.ប ធ្វើការប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រគឺមាន លោក ស ខេង លោក ងិន យន លោកស្រី លី គឹមលៀង លោក ឈាង វុន និងលោក ឡោក ហ៊ួរ ដូច្នេះការផ្លាស់ប្តូរខាងលើនេះ គឺមិនបានឈរលើមូលដ្ឋានរបស់ច្បាប់នោះទេ។

### ៥.៣ ករណីអ្នកតំណាងរាស្ត្រលោក សម រង្ស៊ី

ចំពោះករណីអ្នកតំណាងរាស្ត្រលោក សម រង្ស៊ី វិញខុសប្លែកពីករណីទាំងពីរខាងលើ។ សូមបញ្ជាក់ថា លោកមិនបានឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥នោះទេ ព្រោះលោកត្រូវបាន គ.ជ.ប សម្រេចលុបឈ្មោះចេញពីបញ្ជីឈ្មោះបោះឆ្នោត។

លោក សម រង្ស៊ី បានរកលទ្ធភាពក្លាយជាអ្នកតំណាងរាស្ត្រ ដើម្បីទទួលបានអភ័យឯកសិទ្ធិរដ្ឋសភា នៅបន្ទាប់ពីបេក្ខជនជាប់ឆ្នោតគណបក្សសង្គ្រោះជាតិបានសម្រេចចិត្តចូលរដ្ឋ នៅក្រោយកិច្ចព្រមព្រៀងដំណោះស្រាយនយោបាយរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤។ ទាក់ទងករណីនេះ គណបក្សសង្គ្រោះជាតិបានស្នើទៅ គ.ជ.ប ដើម្បីបញ្ចូលលោក សម រង្ស៊ី ជាបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រក្នុងមណ្ឌលកំពង់ចាម ហើយនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤ គ.ជ.ប បានចេញសេចក្តីសម្រេចចំនួន ៣ គឺ៖

- សម្រេចលុបឈ្មោះបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ និងបេក្ខជនតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ គណបក្សសង្គ្រោះជាតិចេញពីមណ្ឌលខេត្តកំពង់ចាម ចំនួន ២៧នាក់។
- សម្រេចទទួលស្គាល់បញ្ជីបេក្ខជនបម្រុងបន្ថែមផ្លូវការគណបក្សសង្គ្រោះជាតិ សម្រាប់បេក្ខជនតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម នីតិកាលទី៥ ឆ្នាំ២០១៣ ចំនួន ២៧នាក់។
- ទទួលស្គាល់លោក សម រង្ស៊ី ជាបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ របស់គណបក្សសង្គ្រោះជាតិនៅមណ្ឌលកំពង់ចាម។

លោកសម រង្ស៊ី ត្រូវបានរដ្ឋសភាប្រកាសសុពលភាពអាណត្តិរបស់ខ្លួនជាសមាជិកតំណាងរាស្ត្រ នីតិកាលទី៥ នៅក្នុងកិច្ចប្រជុំពេញអង្គវិសាមញ្ញមួយ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤។ នៅកិច្ចប្រជុំនោះលោក ហេង សំរិន ប្រធានរដ្ឋសភា បានអានប្រកាសលេខ ១៧៤ រ.ស ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤ របស់រដ្ឋសភា។ សេចក្តីប្រកាសនោះបានយោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សេចក្តីសម្រេចរបស់ គ.ជ.ប លិខិតស្នើសុំរបស់គណបក្សសង្គ្រោះជាតិ និងការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភានៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤ ដោយបានសម្រេចដូចក្រោម៖

- ប្រការ១ ទទួលស្គាល់លោក សម រង្ស៊ី ជាតំណាងរាស្ត្រមណ្ឌលកំពង់ចាម ជំនួសលោក គួយ ប៊ុនរឿន ដែលបានសុំលាលែង។
- ប្រការ២ តំណាងរាស្ត្រថ្មីដែលមានចែងក្នុងប្រការ១ ត្រូវធ្វើសច្ចាប្រណិធាន។
- ប្រការ៣ អគ្គលេខធិការ នៃអគ្គលេខាធិការដ្ឋាននៃរដ្ឋសភាត្រូវបិទផ្សាយសេចក្តីប្រកាសក្នុងរដ្ឋសភា និងផ្សព្វផ្សាយជាសាធារណៈ។

លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ បង្ហាញថា គណបក្សសង្គ្រោះជាតិទទួលបាន១០អាសនៈនៃអាសនៈសរុប១៨ ក្នុងមណ្ឌលកំពង់ចាម។ គ្រាន់តែត្រូវការដោះដូរ ដើម្បីឱ្យលោក សម រង្ស៊ី ក្លាយជាតំណាងរាស្ត្រ គណបក្សសង្គ្រោះជាតិ គ.ជ.ប និងរដ្ឋសភាបានបំពានទៅលើសិទ្ធិរបស់បេក្ខជននៅក្នុងបញ្ជីបេក្ខជនពេញសិទ្ធិ និងបេក្ខជនបម្រុងរបស់គណបក្សនេះចំនួន២៦នាក់ មិនអាចក្លាយជាអ្នកតំណាងរាស្ត្រតាមលំដាប់លេខរៀងឈរឈ្មោះក្នុងបញ្ជីបេក្ខជនដូចមានបញ្ញត្តិក្នុងច្បាប់បោះឆ្នោត។

គ.ជ.ប មិនបានយោងមាត្រាច្បាប់ ប៉ុន្តែបានធ្វើសេចក្តីសម្រេចដោយមិនមានតម្លាភាពក្នុងការអនុវត្តតាមបញ្ញត្តិនៃមាត្រា ១១៨ ចំណុច **ឃ** និងមាត្រា ១២០ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងវិសោធនកម្មនៃច្បាប់នេះ។ មិនមាន និងភ័ន្តច្រឡំនីតិវិធីរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋ និងរដ្ឋភាឯកបក្សដែលខ្វះនីត្យានុកូលភាព ក្នុងការប្រកាសសុពលភាពលោក សម រង្ស៊ី ជាសមាជិកតំណាងរាស្ត្រ។

## VI. សង្ខេបព្រឹត្តិការណ៍សំខាន់ៗទាក់ទងសភា និងតំណាងរាស្ត្រ

### សារាចរណែនាំរបស់ប្រធានរដ្ឋសភាមិនស្របតាមក្របខ័ណ្ឌច្បាប់ និងគោលការណ៍ប្រសិទ្ធភាព តម្លាភាព និងប្រជាធិបតេយ្យ

សារាចរណែនាំស្តីពីបែបបទការងារស្តីពីគណៈកម្មការនានានៃរដ្ឋសភា ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ ចេញដោយប្រធានរដ្ឋសភា ត្រូវបានអ្នកឃ្លាំមើលដំណើរការរបស់រដ្ឋសភា ធ្វើការចោទប្រកាន់ថា មិនស្របតាមគោលការណ៍ប្រជាធិបតេយ្យ តម្លាភាព ប្រសិទ្ធភាព និងរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា។ ក្រុមអ្នកឃ្លាំមើលបានលើកឡើងនូវបញ្ហាមួយចំនួនដូចខាងក្រោមទាក់ទងនឹងសារាចរណែនាំ៖

បញ្ហាទី១៖ រដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា មិនមានចែងមាត្រាណាមួយផ្តល់អំណាចឱ្យប្រធានរដ្ឋសភាចេញ "សារាចរ ឬបទបញ្ជាឯកត្តភូត" ដើម្បីកំណត់សិទ្ធិអំណាច និងបែបបទការងារផ្ទៃក្នុងរបស់គណៈកម្មការជំនាញនានានៃរដ្ឋសភា។

បញ្ហាទី២៖ សារាចរណែនាំរបស់ប្រធានរដ្ឋសភានេះ ដកសិទ្ធិគណៈកម្មការជំនាញរបស់រដ្ឋសភា ដែលចែងថា "គណៈកម្មការពុំត្រូវអញ្ជើញសង្គមស៊ីវិល ឬសាធារណជនមកចូលរួមប្រជុំរបស់ខ្លួនឡើយ"។ សារាចរនេះ ទំនងជាបកស្រាយ ប្រការ១២ នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាចែងថា គណៈកម្មការនីមួយៗអាចស្នើសុំប្រធានរដ្ឋសភាចាត់តាំងអ្នកជំនាញចូលរួម "ធ្វើការ" បាន។ ការចូលរួម "ធ្វើការ" មិនមានន័យដូចការចូលរួម "ប្រជុំ" ជាមួយគណៈកម្មការជំនាញទេ។

បញ្ហាទី៣៖ សារាចរណែនាំរបស់ប្រធានរដ្ឋសភាបានចែងថា ក្នុងការប្រជុំសុំការបំភ្លឺជុំវិញការអនុវត្តន៍ច្បាប់ គណៈកម្មការពុំត្រូវអញ្ជើញសង្គមស៊ីវិល ឬអ្នកសារព័ត៌មានមកសង្កេតការណ៍ទេ ត្បិតមានតែរដ្ឋមន្ត្រី ឬតំណាងរាជរដ្ឋាភិបាលប៉ុណ្ណោះដែលមានភារកិច្ចមកបំភ្លឺជូនគណៈកម្មការ។ សារាចរនេះ បានរាំងការចូលរួមសង្កេតការណ៍ក្នុងការប្រជុំដេញដោលរវាងគណៈកម្មការជំនាញនៃរដ្ឋសភា និងរដ្ឋមន្ត្រី ឬតំណាងរាជរដ្ឋាភិបាល។ ចំណុចនេះ បង្ហាញកាន់តែច្បាស់ថា សារាចរណែនាំនេះ ធ្វើឲ្យការចោទសួរដេញដោលរវាងគណៈកម្មការនានា និងរដ្ឋមន្ត្រី ឬតំណាងរាជរដ្ឋាភិបាលមិនមានតម្លាភាព។ ការមិនអនុញ្ញាតឲ្យអ្នកសារព័ត៌មាន ឬអ្នកសង្កេតការណ៍របស់អង្គការសង្គមស៊ីវិលចូលយកព័ត៌មាន ឬសង្កេតក្នុងការសួរដេញដោលនេះ គឺពិតជារំលោភលើសិទ្ធិទទួលព័ត៌មានរបស់ប្រជាពលរដ្ឋ។ ម្យ៉ាងវិញទៀត វាជាការចាំបាច់ក្នុងការសង្កេតការណ៍ពីដំណើរការសួរដេញដោល ឬឆ្លើយបំភ្លឺរវាង

គណៈកម្មការ និងរដ្ឋមន្ត្រី ឬតំណាងរាជរដ្ឋាភិបាល ព្រោះវាបង្ហាញពីគណនេយ្យភាពរបស់តំណាងរាស្ត្រ និងរាជរដ្ឋាភិបាលដល់ប្រជាពលរដ្ឋជាម្ចាស់ឆ្នោត។

បញ្ហាទី៤៖ ខ្លឹមសារសារាចរណែនាំនេះ គឺមិនស្របនឹងកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយកាលពីថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៤ ដែលគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានព្រមព្រៀងគ្នាថា ធានាឲ្យដំណើរការស្ថាប័នរដ្ឋសភាមានប្រសិទ្ធភាព តម្លាភាពស្របតាមគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស និងរបបសភានិយម និងលើកកំពស់តួនាទីគណបក្សប្រឆាំងក្នុងរដ្ឋសភា។ គណបក្សទាំងពីរក៏បានស្រុះស្រួលគ្នាថា បន្តពិភាក្សាដំណាក់កាលទីពីរដើម្បីធ្វើវិសោធនកម្ម និងកែលំអបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។

ម្យ៉ាងទៀត ក្រុមអ្នកឃ្លាំមើលបានសំដែងការខកចិត្តចំពោះឥរិយាបថ និងរបៀបរបបការិយាធិបតេយ្យរបស់រដ្ឋបាលនៃរដ្ឋសភា និងអគ្គលេខាធិការដ្ឋានដែលគ្មានការផ្លាស់ប្តូរតាំងពីនីតិកាលមុនៗ ក្នុងការបង្កការលំបាកការទំនាក់ទំនងឯកសារ និងលិខិតនានាជាមួយតំណាងរាស្ត្រ។

គណៈកម្មការជំនាញមួយចំនួនដឹកនាំដោយគណបក្សប្រឆាំង (គណបក្សសង្គ្រោះជាតិ) បានខិតខំធ្វើសកម្មភាពរបស់ខ្លួនក្នុងការកោះហៅប្រជុំសួរយោបល់ និងដេញដោល ខណៈពេលដែលប្រធានរដ្ឋសភាមកពីគណបក្សកាន់អំណាច និងអគ្គលេខាធិការដ្ឋានហាក់មានចេតនាត្រួតត្រាលើគណៈកម្មការជំនាញនានា តាមរយៈការចេញសារាចរនេះ និងការរារាំងរបស់រដ្ឋបាល និងអគ្គលេខាធិការដ្ឋានអំពីការទាក់ទងជាមួយតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា។

## ដំណើរការរបស់រដ្ឋសភាក្នុងរយៈពេលដែលតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិធ្វើពហិការមិនចូលរួម

### ក.រដ្ឋសភាឯកបក្សទទួលខុសត្រូវរិះគន់

ចាប់ពីខែកញ្ញា ឆ្នាំ២០១៣ ដល់ខែកក្កដា ឆ្នាំ២០១៤ គណបក្សប្រជាជនបានរៀបចំអង្គការនីតិបញ្ញត្តិដែលគ្រប់គ្រងតួនាទីដឹកនាំក្នុងរដ្ឋសភាទាំងអស់ ទាំងប្រធាន អនុប្រធានរដ្ឋសភា និងប្រធានគណៈកម្មការជំនាញទាំង៩។

ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ គឺជាកាលបរិច្ឆេទនៃកិច្ចប្រជុំដំបូងនៃការបង្កើតរដ្ឋសភានីតិកាលទី៥។ វាក្យខណ្ឌទី០១ មាត្រា ៨២ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា រដ្ឋសភាបើកសម័យប្រជុំដំបូង៦០ថ្ងៃយ៉ាងយូរ**«ក្រោយពេលបោះឆ្នោត»** តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។ ខុមហ្វ្រែលយល់ថា ជាបច្ចេកទេសនៅមានរយៈច្រើនក្នុងការអនុវត្តន៍ មាត្រា៨២ខាងលើ ព្រោះថា «ក្រោយការបោះឆ្នោត» គឺនិយាយទៅដល់ពេលបញ្ចប់ការបោះឆ្នោត ឬពេលប្រកាសលទ្ធផលបោះឆ្នោតចុងក្រោយ។ ដូចនេះក្រោយពេលបោះឆ្នោតគឺ ចាប់តាំងពីក្រោយថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៣ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតនោះ។ កិច្ចប្រជុំរដ្ឋសភាដំបូងដែលឆ្លើយតប តាមមាត្រា៨២ខាងលើ អាចត្រូវបានពន្យារពេលរហូតដល់

ដើមខែវិច្ឆិកា។ ការពន្យារពេលនេះគឺទុកពេលវេលាឲ្យគណបក្ស ប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិមានពេលវេលាគ្រប់គ្រាន់ដើម្បីចរចាស្វែងរកដំណោះស្រាយជម្លោះក្រោយការបោះឆ្នោត។ មាត្រាច្បាប់ខាងលើបានសរសេរថា រដ្ឋសភាបើកសម័យប្រជុំដំបូង៦០ថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត។ ក្រោយពេលបោះឆ្នោតសំដៅទៅលើពេលដែលដំណើរនៃការបោះឆ្នោតទាំងមូលបានបញ្ចប់ មានន័យថា ក្រោយការបោះឆ្នោតទទួលបានលទ្ធផលផ្លូវការ មិនមែនសំដៅទៅលើក្រោយកាលបរិច្ឆេទណាមួយដែលបានកំណត់ក្នុងប្រតិទិនបោះឆ្នោតដូចជាថ្ងៃបោះឆ្នោតជាដើមនោះទេ។

នៅក្នុងកិច្ចប្រជុំរដ្ឋសភាដំបូងកាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ មានតែបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រចំនួន៦៨រូប មកពីគណបក្សប្រជាជនកម្ពុជាទេ បានចូលរួមក្នុងកិច្ចប្រជុំដំបូងនោះ ដោយមិនមានវត្តមានបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រចំនួន ៥៥រូបរបស់គណបក្សសង្គ្រោះជាតិ។ ក្នុងដំណើរការនេះ បេក្ខជនជាប់ឆ្នោត ចំនួន៦៨រូបមកពីគណបក្ស ប្រជាជនកម្ពុជា បានក្លាយជាសមាជិកជាតំណាងរាស្ត្រ ខណៈពេលដែលបេក្ខជនជាប់ឆ្នោត ៥៥រូបរបស់គណបក្សសង្គ្រោះជាតិ មិនទាន់ក្លាយជាសមាជិកតំណាងរាស្ត្រនៅឡើយទេ។

ម្យ៉ាងវិញទៀត នេះបង្ហាញថា រដ្ឋសភាត្រូវបានបង្កើតដោយគ្មានការចូលរួមពីពហុបក្ស ក្នុងការឆ្លើយតបនឹងមាត្រា០១នៃរដ្ឋធម្មនុញ្ញដែលចែងថា ព្រះរាជាណាចក្រកម្ពុជាតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ម្យ៉ាងវិញទៀត ការបើកប្រជុំបង្កើតរដ្ឋសភាដំបូងក្រោមព្រះរាជាធិបតីភាពរបស់ព្រះមហាក្សត្រ ដែលមិនទាន់មានឯកភាពជាតិដូច្នេះគឺពិតជាមិនបានអនុវត្តតាមមាត្រា០៨នៃរដ្ឋធម្មនុញ្ញដែលបានចែងត្រង់វាក្យខ័ណ្ឌទី១ថា ព្រះមហាក្សត្រព្រះអង្គជានិមិត្តរូបនៃឯកភាពជាតិ។

ដំណើរការ និងនីតិវិធីនាពេលបច្ចុប្បន្ន គឺពឹងផ្អែកទាំងស្រុងទៅលើឆន្ទៈគណបក្សនយោបាយតែមួយគត់ ហើយក្នុងបរិបទនយោបាយប្រទេសកម្ពុជា គណបក្សនយោបាយមានអំណាច និងមានឥទ្ធិពលក្នុងការគ្រប់គ្រងបេក្ខជនជាប់ឆ្នោត ឬតំណាងរាស្ត្ររបស់គណបក្សខ្លួន។

### ខ. ព្រះមហាក្សត្រ និងរដ្ឋសភា

ក្នុងសម័យប្រជុំរបស់ខ្លួនលើកទី២ នីតិកាលទី៥ ព្រះមហាក្សត្រក៏បង្ហាញពីព្រះរាជហឫទ័យរបស់ព្រះអង្គតាមរយៈព្រះរាជសាររបស់ទ្រង់ ដោយសង្ឃឹមថា រដ្ឋសភា ដែលតំណាងប្រជាពលរដ្ឋខ្មែរទាំងមូលនឹងបន្តខិតខំប្រឹងប្រែងដោះស្រាយបញ្ហាប្រឈមនានា ដើម្បីសម្រេចឲ្យបាននូវទិសដៅរួមរបស់កម្ពុជាជាជំហានៗ ធានាបាននូវសង្គមកម្ពុជាមួយដែលរឹងមាំ មានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម មានការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងសមធម៌។ ព្រះរាជសារបន្តថា ជាមួយនឹងការប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នូវគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ជាសង្គមមួយដែលមានកោសិកា

ផ្សារភ្ជាប់គ្នា និងត្រូវពង្រឹងដើម្បីធានាថា ប្រជាជនកម្ពុជាមានចំណេះដឹងខ្ពស់ និងមានវប្បធម៌ល្អប្រសើរ ថ្លៃថ្នូរមានជីវភាពសមរម្យ និងមានការរស់នៅប្រកបដោយសុខដុមរមនាទាំងក្នុងរង្វង់គ្រួសារ និងសង្គមជាតិ។

### ចំណាត់ការរបស់តុលាការលើថ្នាក់ដឹកនាំ និងបេក្ខជនជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ

### ក.តុលាការកោះហៅមេដឹកនាំគណបក្សសង្គ្រោះជាតិ

សាលាដំបូងរាជធានីភ្នំពេញ បានកោះហៅមេដឹកនាំគណបក្សសង្គ្រោះជាតិលោក សម រង្ស៊ី និងលោក កឹម សុខា ដែលជាបេក្ខជនជាប់ឆ្នោត និងជាអនុប្រធានគណបក្សសង្គ្រោះជាតិឲ្យចូលបំភ្លឺជុំវិញបាតុកម្មអហឹង្សារបស់កម្មករ។ ទាក់ទងអភ័យឯកសិទ្ធិនេះមានចំណោទសួរថា តើបេក្ខជនជាប់ឆ្នោត លោក កឹម សុខា មានអភ័យឯកសិទ្ធិជាអ្នកតំណាងរាស្ត្រដែរឬទេ?

បើករណីបកស្រាយរបស់គណបក្សប្រជាជនកម្ពុជាការកោះហៅលោក កឹម សុខា ឲ្យចូលខ្លួនមកបំភ្លឺនៅក្នុងតុលាការនោះ មានការបកស្រាយថា ជាឧបសគ្គផ្លូវច្បាប់ ជាពិសេសទាក់ទងអភ័យឯកសិទ្ធិ ព្រោះថា កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ រដ្ឋសភាមានតំណាងរាស្ត្រទាំងអស់ចំនួន១២៣រូប ដែលក្នុងនោះមានឈ្មោះលោក កឹម សុខា។ បើយោងតាមមាត្រា៨០នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា «*តំណាងរាស្ត្រខ្មែរមានអភ័យឯកសិទ្ធិ។ តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសម្តែងយោបល់ ឬបញ្ចេញមតិក្នុងបំពេញមុខងាររបស់ខ្លួនសោះឡើយ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីខាងលើនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ ដើម្បីសម្រេច។ សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល។ ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឲ្យផ្អាកតាមមតិភាគច្រើនបីភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល។*»

ក្នុងករណីខាងលើលោក កឹម សុខា ទទួលបានអភ័យឯកសិទ្ធិ ហើយត្រូវបានតុលាការកោះហៅឲ្យចូលខ្លួនមកបំភ្លឺ ដោយពុំមានការស្នើសុំទៅរដ្ឋសភាដើម្បីសុំដកអភ័យឯកសិទ្ធិដូចនេះគឺការរំលោភច្បាប់។

ការអនុវត្តន៍របស់សាលាដំបូងរាជធានីភ្នំពេញនេះ បញ្ជាក់ថា បេក្ខជនជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិមិនត្រូវបានផ្តល់អភ័យឯកសិទ្ធិនោះទេ ហើយមានន័យថា បេក្ខជនជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិក៏មិនទាន់ក្លាយជាអ្នកតំណាងរាស្ត្រដែរ ដូច្នេះគេអាចនិយាយបានថា ដំណើរការរដ្ឋសភានីតិកាលទី៥នេះ នៅមិនទាន់ស្របច្បាប់នៅឡើយ ព្រោះថា បើពិនិត្យទៅលើមាត្រា៧៦នៃរដ្ឋធម្មនុញ្ញដែលចែងថា«*រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច១២០រូប*»។

## ខ.ការចាប់ខ្លួនបេក្ខជនតំណាងរាស្ត្រ

បេក្ខជនជាប់ឆ្នោតប្រាំពីរ (៧)រូប នៃគណបក្សសង្គ្រោះជាតិរួមមាន លោកស្រី មូរ សុខហួរ លោក ម៉ែន សុថាវរិន្ទ្រ លោក ហូរ វ៉ាន់ លោក រៀល ខេមរិន្ទ្រ លោក កែវ ភីរម្យ លោក ឡុង រី និង លោក នុត រំដួល កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ និងថ្ងៃបន្តបន្ទាប់ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញចាប់ឃុំខ្លួន និងត្រូវបានចោទប្រកាន់ពីបទផ្តើមគំនិតឲ្យមានកុបកម្ម ដឹកនាំធ្វើកុបកម្មហឹង្សាមានស្ថានទម្ងន់ទោស និងបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ។ ការចាប់ខ្លួន និងការចោទប្រកាន់នេះធ្វើឡើងនៅបន្ទាប់ពីបេក្ខជនជាប់ឆ្នោតទាំងនោះបានដឹកនាំបាតុកម្មទាមទារឱ្យមានការដោះលែងទីលានប្រជាធិបតេយ្យ ហើយមានការប៉ះទង្គិចដោយអំពើហឹង្សាមួយបានកើតឡើង ដែលបណ្តាលឱ្យក្រុមសន្តិសុខរបស់ខណ្ឌដូនពេញ និងសកម្មជនគណបក្សសង្គ្រោះជាតិប្រមាណជាង៥០នាក់បានរងរបួស។

ជុំវិញការចាប់ខ្លួននេះ មានការចោទប្រកាន់រាជរដ្ឋាភិបាលថា ជាចេតនាដើម្បីចាប់បង្ខំឲ្យចូលតុចរចា បន្ទាប់ពីបានជាប់គាំងនយោបាយជាច្រើនខែនៅក្រោយការបោះឆ្នោត។ អ្នកឃ្លាំមើលសិទ្ធិមនុស្សក៏បានរិះគន់ថា ដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា កំពុងធ្លាក់ចុះយ៉ាងគំហុក និងមានស្ថានភាពធ្ងន់ធ្ងរក្រៃលែង និងបានរុញច្រានស្ថានភាពនយោបាយនៅកម្ពុជាឲ្យកាន់តែមានភាពតានតឹងបន្ថែមទៀត ហើយការចាប់ខ្លួននេះជារឿងនយោបាយ។

ដោយឡែកថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិ បានបញ្ជាក់ថា ការចាប់ខ្លួននេះគឺជារឿងនយោបាយ ហើយវាអយុត្តិធម៌ខ្លាំងណាស់ចំពោះគណបក្សប្រឆាំង។ ជាមួយគ្នានេះក៏មានការលើកឡើងអំពីអភ័យឯកសិទ្ធិសភារបស់បេក្ខជនជាប់ឆ្នោតទាំងនោះ បើពួកគេមានអភ័យឯកសិទ្ធិ ការអនុវត្តនីតិវិធីរបស់តុលាការ គឺរំលោភច្បាប់ ប៉ុន្តែក្នុងន័យនេះពួកគេមិនមានអភ័យឯកសិទ្ធិទេ ដូច្នេះការបង្កើតរដ្ឋសភានៅក្រោយការបោះឆ្នោត គឺមិនស្របច្បាប់។

ការចាប់ខ្លួននេះបានធ្វើឱ្យមានការចាប់អារម្មណ៍ពីសំណាក់ឯកអគ្គរដ្ឋទូតប្រចាំនៅកម្ពុជា អង្គការសហប្រជាជាតិ និងសហគមន៍អឺរ៉ុប។ គួរបញ្ជាក់ថា ឯកអគ្គរដ្ឋទូត តំណាងអង្គការសហប្រជាជាតិ និងសហគមន៍អឺរ៉ុបសរុបចំនួន២៤រូប បានចូលរួមស្តាប់ការពន្យល់របស់ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ជុំវិញអំពើហឹង្សា និងការចាប់ខ្លួនបេក្ខជនជាប់ឆ្នោតទាំងនេះ។ ជាមួយគ្នានេះក៏បានជំរុញឲ្យគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិបញ្ចប់ជម្លោះ ហើយទទូចឲ្យមានការដោះលែងបេក្ខជនជាប់ឆ្នោត និងមន្ត្រីគណបក្សសង្គ្រោះជាតិដែលត្រូវបានឃុំខ្លួនទាំងនោះ។ ជាមួយគ្នាប្រជាពលរដ្ឋ អង្គការជាតិ និងអន្តរជាតិ ក៏បានទាមទារឱ្យមានការដោះលែងផងដែរ។

អ្នកទាំងនោះត្រូវបានដោះលែងវិញភ្លាមៗ នៅបន្ទាប់ពីកិច្ចចរចាថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ រវាងថ្នាក់ដឹកនាំកំពូលនៃគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ និងបានឯកភាពគ្នាទម្លាយភាពជាប់គាំងនយោបាយ ដោយបេក្ខជនជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិចូលរួមក្នុងរដ្ឋសភា។ បើទោះជាមានការដោះលែងក៏ដោយ ក៏តុលាការនៅបន្តនីតិវិធីរបស់ខ្លួន ដោយបានកោះហៅអ្នកទាំងនៅទៅបំភ្លឺនៅតុលាការនៅក្រោយការដោះលែង និងព្រមទាំងមានការចាប់ខ្លួនមន្ត្រី និងសកម្មជនគណបក្សសង្គ្រោះជាតិជាបន្តបន្ទាប់ទាក់ទងករណីដូចគ្នានេះ។

## សកម្មភាពរបស់បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រត្រូវបានរារាំង

កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៤ មានបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិចំនួន៤រូបត្រូវបានកងកម្លាំងសមត្ថកិច្ចចម្រុះស្រុកអន្លង់វែង បានធ្វើការរារាំងមិនឲ្យធ្វើដំណើរទៅចូលរួមវេទិកាសំណេះសំណាលជាមួយប្រជាពលរដ្ឋនៅក្នុងខេត្តឧត្តរមានជ័យ។ នៅស្របពេលនោះដែរ កម្លាំងសមត្ថកិច្ចក៏បានដកហូតនូវសម្ភារមួយចំនួនពីបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រទាំងនោះផងដែរ។

ករណីនេះបានជះឥទ្ធិពលអវិជ្ជមានទៅលើក្រុមបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ ក្នុងការបំពេញតួនាទីរបស់ខ្លួន ជាពិសេសសកម្មភាពជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ ដែលជាម្ចាស់ឆ្នោត ដើម្បីទទួលស្តាប់អំពីបញ្ហាកង្វល់នានា និងអន្តរាគមន៍ដើម្បីរកដំណោះស្រាយ។

បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រចំនួន៤រូបនោះរួមមាន បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ ប៉ុល ហំម មណ្ឌលតាកែវ បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ ពិន រតនា មណ្ឌលបាត់ដំបង បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ អ៊ុច សេរីយុទ្ធ មណ្ឌលកំពង់ចាម និងបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ ទូត យឿត មណ្ឌលព្រៃវែង។ គួរបញ្ជាក់ថា បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រទាំង៤រូប ត្រូវបានក្រុមសមត្ថកិច្ចចម្រុះ និងរួមទាំងជនស៊ីវិលជាច្រើនរយនាក់ដែលមានកាន់វិទ្យុទាក់ទង ប្រដាប់ដំបង និងកាំភ្លើងដែលបានប្រមូលផ្តុំគ្នាតាមដងផ្លូវ និងបង្កប់នៅក្នុងភូមិសាស្ត្រព្រៃស្អាក ធ្វើសកម្មភាពរារាំង និងបានដកហូតទូរស័ព្ទដៃចំនួន៨គ្រឿង និងអាយផេត(iPad)ចំនួន៥គ្រឿង នៅខណៈពេលដែលបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រទាំងនោះ និងក្រុមការងាររបស់ខ្លួនធ្វើដំណើរទៅជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត។

តាមប្រសាសន៍របស់ប្រធានគណបក្សសង្គ្រោះជាតិប្រចាំខេត្តឧត្តរមានជ័យ ក្នុងសារព័ត៌មានបានបញ្ជាក់ឱ្យដឹងថា មានជនស៊ីវិលជាច្រើនរយនាក់ដែលដាក់នៅតាមដងផ្លូវ ប្រដាប់ដោយកាំភ្លើង ដំបង និងមានកាន់វិទ្យុទាក់ទងផងនោះ ជាកងកម្លាំងយោធាស្លៀកពាក់ស៊ីវិលមកពីកងពលតូចថ្មើរជើងលេខ៤១ និងមកពីប្រាសាទតាមាន់ ដើម្បីរង់ចាំរារាំងប្រធានគណបក្សសង្គ្រោះជាតិ លោក សម រង្ស៊ី និងអនុប្រធាន លោក កឹម សុខា មិនឲ្យសំណេះណាលជាមួយសកម្មជន និងអ្នកគាំទ្ររបស់គណបក្ស។

ករណីដកហូតសម្ភារទាំងនេះ ត្រូវបានសមាជិកព្រឹទ្ធសភាភូមិភាគទី៤របស់គណបក្សសម រង្ស៊ី លោក ហុង សុខហួរ បានដាក់លិខិតផ្ញើជូន លោក ស ថាវី អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ដើម្បីសុំជួយអន្តរាគមន៍ឱ្យកម្លាំងសមត្ថកិច្ចស្រុកអន្លង់វែង ប្រគល់វិញនូវសម្ភារៈដែលបានដកហូតដោយខុសច្បាប់ទាំងនោះ មកពេលនេះនៅមិនទាន់ទទួលព័ត៌មានណាមួយពីការធ្វើអន្តរាគមន៍របស់លោកអភិបាលខេត្តនោះទេ។

ដោយឡែក នៅក្នុងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ កឹម សុខា មណ្ឌលកំពង់ចាមពីគណបក្សសង្គ្រោះជាតិ រួមទាំងថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិ ត្រូវបានក្រុមអ្នកតវ៉ាប្រមាណ១០០នាក់បានធ្វើសកម្មភាពរារាំងក្រុមលោកមិនឱ្យចូលជួបប្រជាពលរដ្ឋម្ចាស់ឆ្នោត ក្នុងគម្រោងសំណេះសំណាលមួយ

ក្នុងក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ ក្រុមអ្នកតវ៉ាទាំងនោះបានសំអាងហេតុផលថា ការរារាំងនេះមកពីប្រជាពលរដ្ឋនៅក្នុងខេត្តនេះមិនត្រូវការវត្តមានអ្នកដឹកនាំបក្សប្រឆាំងនៅក្នុងតំបន់រស់នៅរបស់ពួកគេឡើយ។ ជុំវិញបញ្ហានេះ មានការលើកឡើងថា មានអ្នកនៅពីក្រោយការតវ៉ានេះ បានញុះញង់ឱ្យក្រុមអ្នកតវ៉ាអ្នកនោះធ្វើសកម្មភាពរារាំងនេះ ដើម្បីបន្ទច់បង្អាក់សកម្មភាពរបស់ថ្នាក់ដឹកនាំគណបក្សប្រឆាំង។

## ការអនុម័តច្បាប់ទាក់ទងវិស័យតុលាការរបស់រដ្ឋសភាដែលខ្វះភាពស្របច្បាប់

សេចក្តីព្រាងច្បាប់ចំនួន៣ដែលរដ្ឋសភាជាតិឯកបក្ស គ្មាននីត្យានុកូលភាពយកមកពិភាក្សា និងអនុម័តក្នុងសម័យប្រជុំលើកទី២នីតិកាលទី៥នេះ ត្រូវបានក្រុមអង្គការសង្គមស៊ីវិលមួយចំនួនមានការព្រួយបារម្ភ និងស្នើសុំឲ្យរដ្ឋសភាផ្អាកការពិភាក្សា និងអនុម័តរហូតដល់មានការផ្សព្វផ្សាយ និងបើកឲ្យមានកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងរហូតដល់តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិចូលរដ្ឋសភា។

សេចក្តីព្រាងច្បាប់ពាក់ព័ន្ធវិស័យតុលាការទាំងបីនោះ ត្រូវបានរដ្ឋសភាយកមកពិភាក្សា និងអនុម័តនៅថ្ងៃទី២២ និង២៣ ខែឧសភា ឆ្នាំ២០១៤។ ក្រុមអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិបានរិះគន់ថា ដំណើរបង្កើតច្បាប់ទាំងនេះរបស់រាជរដ្ឋាភិបាល ពុំមានការផ្សព្វផ្សាយ និងបើកឱ្យភាគីពាក់ព័ន្ធពិគ្រោះយោបល់ មុនបញ្ជូនទៅរដ្ឋសភាពិភាក្សានិងអនុម័ត។ ជាមួយគ្នាក៏មានការរិះគន់ថា ច្បាប់ទាំងបីនេះបានធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យភាពតុលាការ និងបានផ្តល់ឱ្យស្ថាប័ននីតិប្រតិបត្តិមានឥទ្ធិពលទៅលើស្ថាប័នតុលាការបន្ថែមទៀតផង។

មន្ត្រីអង្គការសង្គមស៊ីវិលធ្វើការទាក់ទងវិស័យតុលាការបានលើកឡើងថា សេចក្តីព្រាងច្បាប់ទាំងបីនោះមានចំណុចល្អ និងចំណុចមិនច្បាស់លាស់មួយចំនួនដូចជា ការផ្តល់អំណាចទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ខ្លាំងពេក ដែលចៅក្រម និងព្រះរាជអាជ្ញាហាក់នៅក្រោមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយមានចំណុចពីរទៀត ដែលចាត់ចែងដោយក្រសួងយុត្តិធម៌ ដែលទី១ គឺអគ្គលេខាធិការដ្ឋាន និងទី២ក្រុមអធិការកិច្ច។ ទន្ទឹមនឹងនេះ អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិក៏បានអំពាវនាវឲ្យរាជរដ្ឋាភិបាលកម្ពុជាដកសេចក្តីព្រាងច្បាប់ទាំងនេះវិញ និងស្នើឲ្យម្ចាស់ជំនួយចាត់វិធានការដើម្បីធានាថា ប្រព័ន្ធតុលាការពិតជាមានភាពឯករាជ្យ។

សេចក្តីព្រាងច្បាប់ទាំង៣នោះរួមមាន៖ សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការដែលមាន ៨ជំពូកចែងជា៩១មាត្រា, សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅកម្មដែលមាន ៦ជំពូកចែងជា៣១មាត្រា និងសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលមាន៦ជំពូកចែងជា ១១១មាត្រា។

ជុំវិញបញ្ហានេះ មន្ត្រីជាន់ខ្ពស់របស់គណបក្សប្រជាជនកម្ពុជា លោក ជាម យៀប អ្នកតំណាងរាស្ត្រមណ្ឌលព្រៃវែងបានមានប្រសាសន៍ថា « *បើសិនជាសង្គមស៊ីវិលខាងសិទ្ធិមនុស្សសុំផ្អាកនោះ ឲ្យគាត់រៀបចំធ្វើច្រវាក់ដែកថៃបឲ្យទប់ស្កាត់ធ្វើយ៉ាងម៉េចដើម្បីកុំឲ្យផែនដីវិល ហើយផែនដីហ្នឹងដើរ អាហ្នឹងអាចធ្វើបាន ព្រោះនេះជាចន្លោមួយរបស់រដ្ឋធម្មនុញ្ញមាតុភូមិកម្ពុជា មិនអាចមករាំងស្ទះបានទេ*»។ ជាមួយគ្នាលោក ក៏បានអះអាថាសភាបច្ចុប្បន្នមាន

បទពិសោធន៍ និងមានចំណេះដឹងគ្រប់គ្រាន់ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់នេះ៖*«ពីព្រោះអ្នក៦៨នាក់នេះ នៅក្នុងសភា ៣០ឆ្នាំផ្លាយហើយ យើងអាចមានលទ្ធភាពយល់អំពីច្បាប់ច្រើនណាស់ទៅហើយ។ តំណាងរាស្ត្រមួយចំនួនធំទៀត លោកមានអតីតកាលបទពិសោធន៍ច្រើន មេរៀនគ្រប់បែបយ៉ាងយល់ពីសភាពការណ៍កម្ពុជា គ្រប់បែបយ៉ាងតែម្តង»*។

ជាមួយគ្នានេះប្រមុខដឹកនាំរាជរដ្ឋាភិបាលបានថ្លែងការពារថា អ្នកផ្តួចផ្តើមធ្វើច្បាប់បានស្តាប់ច្រើនហើយពីប្រជាពលរដ្ឋ ហើយបញ្ញត្តិច្បាប់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ គឺមិនចង្អុលបង្ហាញឲ្យគណៈរដ្ឋមន្ត្រី ប្រគល់សេចក្តីព្រាងច្បាប់ទៅនរណាម្នាក់ គឺមានតែអ្នកព្រាងច្បាប់បញ្ជូនទៅគណៈរដ្ឋមន្ត្រី និងទៅរដ្ឋសភាដើម្បីអនុម័ត។ លោកបញ្ជាក់ថា គណៈរដ្ឋមន្ត្រី មិនមានកន្លែងទៅសុំយោបល់សង្គមស៊ីវិល ហើយសង្គមស៊ីវិល កុំអាលទាមទារសិទ្ធិហួសពេល និងសុំឲ្យមានការអៀនខ្មាស់ និងកុំទាមទារកិច្ចការរបស់គេមកធ្វើ។

## ភាពចម្រូងចម្រាសក្នុងការគោះប្រជុំសភាដំបូងរបស់ព្រះមហាក្សត្រ

ព្រះមហាក្សត្រមានព្រះរាជតួនាទីសំខាន់ណាស់នៅក្នុងការដោះស្រាយភាពទាល់ច្រកនយោបាយ។ ព្រះអង្គមានតួនាទីជាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាឧត្តមក្រុមប្រឹក្សាការពារជាតិ ពិសេសទៅទៀតនោះ នៅពេលប្រទេសមានបញ្ហាផ្នែកនយោបាយ ព្រះអង្គមានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល ដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈឲ្យមានភាពទៀងទាត់។

នៅក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥នេះ គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិដែលទទួលបានអាសនៈក្នុងការបោះឆ្នោតនេះមិនចុះសម្រុងគ្នាចំពោះលទ្ធផលនៃការបោះឆ្នោត និងការចូលរួមបង្កើតរដ្ឋសភាជាដើម។ បញ្ហានេះត្រូវបានគេសង្ឃឹមថា អង្គព្រះមហាក្សត្រ អាចនឹងដើរតួនាទីដើម្បីដោះស្រាយការជាប់គាំងនយោបាយ។ មិនទាន់មានការដោះស្រាយបញ្ហាដំណោះ និងជាប់គាំងនយោបាយ ប៉ុន្តែព្រះមហាក្សត្រ សម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ទ្រង់បានកោះអញ្ជើញបេក្ខជនជាប់ឆ្នោតទាំង ១២៣រូប ដើម្បីចូលរួមប្រជុំរដ្ឋសភាជាលើកដំបូង នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣។

ខ្លឹមសារព្រះរាជសាររបស់ព្រះមហាក្សត្រព្រះបាទ នរោត្តម សីហមុនី បានបញ្ជាក់ថា ព្រះអង្គសូមឯកឧត្តម និងលោកជំទាវ សមាជិកគណបក្សសង្គ្រោះជាតិ មេត្តាអញ្ជើញចូលរួមក្នុងសម័យប្រជុំសភាដំបូង ដើម្បីបង្ហាញនូវការរួបរួមជាតិ និងឯកភាពជាតិ។

ឆ្លើយតបទៅនឹងការកោះអញ្ជើញនេះ បេក្ខជនជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិ ប្រកាសជំហរមិនចូលរួមសម័យប្រជុំសភាដំបូងឡើយ។

ជុំវិញការបើកកិច្ចប្រជុំសភាកាលពីថ្ងៃទី២៣ កញ្ញា ដោយឯកបក្ស ពោលគឺមានតែគណបក្សប្រជាជនកម្ពុជា ត្រូវបានគេមើលឃើញថា កម្ពុជាបានដើរថយពីលទ្ធិប្រជាធិបតេយ្យ និងរំលោភរដ្ឋធម្មនុញ្ញ និងបានធ្វើឲ្យកម្ពុជាបានជួបវិបត្តិនយោបាយអស់រយៈពេលជាង៦ខែមកហើយចាប់តាំងពីបង្កើតរដ្ឋសភា។

### ការចរចារកដំណោះស្រាយនៅក្រោយការបោះឆ្នោតរបស់គណបក្សជាប់ឆ្នោត

បន្ទាប់ពីបរាជ័យក្នុងការចរចា ជាច្រើនលើកច្រើនសារួចមក គណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនកម្ពុជាបានវិលត្រឡប់មករកតុចរចាសាជាថ្មី កាលពីថ្ងៃទី១៨ ខែកុម្ភៈ និងថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៤នេះ ដែលជាជំនួបចរចាលើកទី០៨ហើយនៅថ្ងៃទី០៩និងថ្ងៃទី២០ខែសីហាឆ្នាំ២០១៤ នៅថ្ងៃទី១៤ខែកញ្ញាឆ្នាំ២០១៤ នៅថ្ងៃទី៥ខែវិច្ឆិកាឆ្នាំ២០១៤ នៅថ្ងៃទី១០ខែមិនាឆ្នាំ២០១៤ ក្នុងនោះមានជំនួបថ្នាក់ដឹកនាំកំពូលចំនួនពីរលើកផងដែរនៅថ្ងៃ១៦ និង១៧ ខែកញ្ញា ឆ្នាំ២០១៣។ បើទោះជាមានការព្រមព្រៀងលើការកែទម្រង់ការបោះឆ្នោតនូវការចរចាចុងក្រោយនេះ ការមិនចុះសម្រុងគ្នាកន្លងមក ត្រូវបានមើលឃើញថា កើតមកពីការមិនទុកចិត្តគ្នា និងការបកស្រាយរដ្ឋធម្មនុញ្ញផ្ទុយគ្នា។

ជម្លោះនយោបាយកើតឡើង នៅបន្ទាប់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានប្រកាសថា គណបក្សប្រជាជនកម្ពុជាឈ្នះឆ្នោតដោយទទួលបានអាសនៈចំនួន៦៨ រីឯគណបក្សសង្គ្រោះជាតិទទួលបាន៥៥ កៅអី។ ជម្លោះនេះបានធ្វើឲ្យកម្ពុជាបានជួបវិបត្តិនយោបាយអស់រយៈពេលជាង៦ខែមកហើយ។

ជុំវិញលទ្ធផលនេះ គណបក្សសង្គ្រោះជាតិតែងតែអះអាងថា គណបក្សរបស់ខ្លួនជាអ្នកឈ្នះការបោះឆ្នោតនេះ ពោលគឺឈ្នះ៦៣អាសនៈក្នុងចំណោមអាសនៈសរុប ១២៣។ ជម្លោះនយោបាយនៅក្រោយការបោះឆ្នោតនេះ វាតែងតែកើតមានឡើង ហើយសម្រាប់អាណត្តិទី៥នេះបាន និងបន្តអូសបន្លាយ ហើយដំណោះស្រាយនៃបញ្ហានេះហាក់នៅវែងឆ្ងាយនៅឡើយ។

អាជ្ញាធរបានចាត់វិធានការបំបែកការតវ៉ា និងបានដាក់បំរាមហាមឃាត់ការជួយជុំតវ៉ានានា ចាប់ការបំបែកការតវ៉ាដឹកនាំដោយគណបក្សសង្គ្រោះជាតិនៅទីលានប្រជាធិបតេយ្យកាលពីថ្ងៃទី០៤ ខែមករា ហើយបានចេញបំរាមមិនឲ្យមានការប្រមូលផ្តុំលើសពី១០នាក់។

ដើម្បីទម្លាយភាពទាល់ច្រកនេះ គណបក្សទាំងពីរគួរលើករបៀបវារៈទាក់ទងកំណែទម្រង់ការបោះឆ្នោត (កំណែទម្រង់ច្បាប់បោះឆ្នោត បញ្ជីបោះឆ្នោត និងអាជ្ញាធររៀបចំការបោះឆ្នោតជាដើម) និងកំណែទម្រង់បញ្ហាជាតិមួយចំនួនទៀត ដោយគណបក្សប្រឆាំងត្រូវចូលរដ្ឋសភា ដើម្បីចូលរួមពិនិត្យ និងអនុម័តច្បាប់ពាក់ព័ន្ធនានា។ លើសពីនេះ ការបែងចែកអំណាច (តុល្យភាពអំណាច) នៅក្នុងរដ្ឋសភាជាតិក៏ជាប្រធានបទដែលគណបក្សទាំងពីរគួរបន្តលើមកពិភាក្សាដើម្បីធានាថា កំណែទម្រង់ទាំងនេះអាចទទួលយកបានរវាងគណបក្សទាំងពីរ និងបំរើឲ្យប្រយោជន៍ជាតិ។

## ជំហរមិនចូលរួមក្នុងសភារបស់គណបក្សសង្គ្រោះជាតិ

នៅបន្ទាប់ពីការប្រជុំសភាដំបូង គណបក្សសង្គ្រោះជាតិបានបញ្ជាក់ជំហរថា បើមិនមានការអង្កេតឯករាជ្យមួយ ដើម្បីរកការពិតទាក់ទងលទ្ធផលការបោះឆ្នោត និងការកែទម្រង់បញ្ហាជាតិសំខាន់ៗទេ បេក្ខជនគណបក្សនេះនឹងមិនចូលរដ្ឋសភាឡើយ។

បន្ថែមលើនេះទៀត កន្លងមកគណបក្សសង្គ្រោះជាតិបានដឹកនាំធ្វើការតវ៉ាបាតុកម្មទ្រង់ទ្រាយធំ មានរាប់សែននាក់ឲ្យលោកនាយករដ្ឋមន្ត្រីហ៊ុន សែន ចុះចេញពីតំណែង ឬត្រូវមានការបោះឆ្នោតឡើងវិញ។ ជាមួយគ្នានេះក៏បានអំពាវនាវសុំសហគមន៍អន្តរជាតិ កុំទទួលស្គាល់រដ្ឋាភិបាលអាណត្តិទី៥នេះ និងបានព្រមានចំពោះក្រុមហ៊ុនអន្តរជាតិធំៗ សុំកុំចុះកុងត្រាជំនួញជាមួយរដ្ឋាភិបាលនេះ ពីព្រោះកុងត្រាទាំងនោះអាចត្រូវបដិសេធនៅពេលអនាគតជាដើម។

## គណបក្សកាន់អំណាចពិចារណាលទ្ធភាពដកហូតអាសនៈគណបក្សសង្គ្រោះជាតិ

ការមិនចូលរដ្ឋសភារបស់បេក្ខជនជាប់ឆ្នោតទាំង៥៥រូបរបស់គណបក្សសង្គ្រោះជាតិ បានបង្កឲ្យមានប្រតិកម្មពីគណបក្សប្រជាជនកម្ពុជា។ ទាក់ទងការធ្វើពហិការមិនចូលរដ្ឋសភានេះ ត្រូវបានលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជាបកស្រាយថា ជាការបោះបង់អាសនៈ ហើយតាមច្បាប់បោះឆ្នោត គ.ជ.ប អាចយកទៅបែងចែកឲ្យគណបក្សផ្សេង។

នៅក្នុងអំឡុងខែធ្នូ ឆ្នាំ២០១៣ មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជាបានបញ្ជាក់ឲ្យដឹងថា ខ្លួនបានពិភាក្សាអំពីលទ្ធភាពស្នើឲ្យមានការទាត់ចោលអាសនៈចំនួន៥៥របស់គណបក្សសង្គ្រោះជាតិ និងគ្រោងស្នើឲ្យមានការធ្វើវិសោធនកម្មច្បាប់បោះឆ្នោត ដើម្បីបញ្ចៀសវិបត្តិក្នុងរដ្ឋសភាក្រោយពីការបោះឆ្នោត ប៉ុន្តែមកដល់ពេលនេះនៅមិនមានការបង្ហាញជាផ្លូវការយ៉ាងណានោះទេចំពោះបញ្ហានេះ។

លើសពីនេះ គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា បានធ្វើរបាយការណ៍ជុំវិញអវត្តមានរបស់បេក្ខជនតំណាងរាស្ត្រនៃគណបក្សសង្គ្រោះជាតិ ដើម្បីទូលថ្វាយព្រះមហាក្សត្រ បញ្ជូនទៅ គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញផងដែរ។ ក៏នៅមិនទាន់មានការបញ្ជាក់ជាផ្លូវការយ៉ាងណាទេចំពោះករណីនេះ។

ជុំវិញករណីនេះដែរ នាពេលថ្មីៗនេះអ្នកតំណាងរាស្ត្រ ជាម យៀប ប្រធានគណៈកម្មការហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភា បានបញ្ជាក់ឲ្យដឹងថា ប្រាក់ខែបេក្ខជនជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិអំឡុងពេល៦ខែកន្លងមកនេះ គឺត្រូវទុកជាសម្បត្តិរដ្ឋ។ បេក្ខជនជាប់ឆ្នោតទាំង ៥៥រូប នឹងទទួលបានប្រាក់ខែនៅបន្ទាប់ពីធ្វើសច្ចាប្រនិធានក្លាយជាតំណាងរាស្ត្រពេញសិទ្ធិ ហើយចំពោះប្រាក់ខែចាស់ គឺស្ថិតនៅលើនាយករដ្ឋមន្ត្រីជាអ្នកកំណត់។

ចំពោះគម្រោងដកហូតអាសនៈនេះ មន្ត្រីជាងខ្ពស់គណបក្សសង្គ្រោះជាតិបានបកស្រាយថា ជាអំពើខុសច្បាប់ និងអាចនឹងរុញច្រានឲ្យកម្ពុជាធ្លាក់ក្នុងវិបត្តិនយោបាយកាន់តែធ្ងន់ធ្ងរ។ ទន្ទឹមនឹងនេះ មន្ត្រីអង្គការសង្គមស៊ីវិល

ក៏បានធ្វើការបកស្រាយថា គម្រោងណាមួយក្នុងដកហូតអាសនៈរបស់គណបក្សសង្គ្រោះជាតិ គឺជាអំពើខុសច្បាប់ ព្រោះថាច្បាប់បោះឆ្នោតបានចែងថា បើមានការប្រកាសបោះបង់ចោលអាសន្ន ទើប គ.ជ.ប អាចយកទៅបែងចែកឲ្យគណបក្សផ្សេង ប៉ុន្តែគណបក្សសង្គ្រោះជាតិមិនដែលប្រកាសបោះបង់ចោលអាសនៈនោះទេ។

## សកម្មភាពបេក្ខជនជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិក្រោយអំឡុងពេលបោះឆ្នោត

ក្រោយពីសភាជាតិនីតិកាលទី៥ បានបង្កើតឡើងដោយការបើកប្រជុំដំបូងក្រោមវត្តមានព្រះមហាក្សត្រ និងបេក្ខជនជាប់ឆ្នោតគណបក្សប្រជាជនកម្ពុជាកាលពីថ្ងៃទី២៤ ខែកញ្ញា ២០១៣ គេសង្កេតឃើញថា បេក្ខជនជាប់ឆ្នោតមកពីគណបក្សសង្គ្រោះជាតិដែលធ្វើពហិការមិនចូលរួមប្រជុំសភាមួយចំនួន បានធ្វើសកម្មភាពយ៉ាងសកម្មក្នុងការចូលរួមរៀបចំ និងដឹកនាំបាតុកម្ម។ ចាប់ពេលបង្កើតសភាឯកបក្ស រហូតដល់ខែមករា ឆ្នាំ២០១៤ គេសង្កេតឃើញមានបាតុកម្មចំនួន២៥លើកនៅរាជធានីភ្នំពេញដែលចូលរួម ឬដែលត្រូវបានរៀបចំ និងដឹកនាំដោយបេក្ខជនជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិ។ បាតុកម្មទាំងនោះធ្វើឡើងក្នុងគោលបំណងដ៏ធំ គឺដើម្បីរកយុត្តិធម៌ជូនប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតដោយទាមទារឲ្យមានការស៊ើបអង្កេតភាពមិនប្រក្រតីនៃការបោះឆ្នោត ឬទាមទារឲ្យមានការបោះឆ្នោតឡើងវិញ។ បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រមួយចំនួនក៏បានចូលរួមក្នុងបាតុកម្មទាមទារតំឡើងប្រាក់បៀវត្សរ៍ផងដែរ។ បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ដែលចូលរួមយ៉ាងសកម្មរួមមាន៖ បេក្ខជន កឹម សុខា មណ្ឌលកំពង់ចាម បេក្ខជន គួយ ប៊ុនរឿន មណ្ឌលកំពង់ចាម បេក្ខជន សុន ឆ័យ មណ្ឌលភ្នំពេញ បេក្ខជន ហូរ វ៉ាន់ មណ្ឌលភ្នំពេញ បេក្ខជន មួរ សុខហួរ មណ្ឌលបាត់ដំបង បេក្ខជនយឹម សុវណ្ណ មណ្ឌលភ្នំពេញ បេក្ខជន កែ សុវណ្ណរតន៍ បេក្ខជន ជូឡុង សូម៉ូរ៉ា មណ្ឌលភ្នំពេញ។